# អត្ថន័យនៃ
# ពិធីជ្រមុជទឹក
## ក្នុងក្រុមជំនុំ
## យូណៃធីតមេថូឌីស្ទ

Mark W. Stamm



# អត្ថន័យ នៃ
# ពិធីជ្រមុជទឹក

## ក្នុង

## ក្រុមជំនុំយូណៃធីតមេថូឌីស្ទ

By Mark W. Stamm

# មាតិការ


សេចក្តីផ្តើម ............................................................................4

ពិធីជ្រមុជទឹកៈ ឬសគល់ពីព្រះគម្ពីរ .........................................................7

ពិធីជ្រមុជទឹកៈ វិធីនៃសេចក្តីសង្គ្រោះ និង ការមើលទៅមុខផ្នែកបេសកកម្ម ..........................11

ឈានជើងចូលក្នុងទឹករស់ៈ ការអនុវត្តន៍ទំនាមទំលាប់នៃពិធីជ្រមុជទឹក ..............................14

តារាងរបស់អ្នកៈ ការរៀបចំសំរាប់ពិធីជ្រមុជទឹក
ដោយសំឡឹងមើលគោលដៅខាងមុខ ...............................................................15

ការបង្កើតក្តីស្រម័យនៃពិធីវិសុទ្ធៈ ទំនាមទំលាប់នៃការប្រើទឹក ...........................................18

តើនេះជាពិធីជ្រមុជទឹករបស់អ្នកណា? តួនាទីផ្សេងៗក្នុងកម្មវិធី ..........................................21

តើអ្វីនឹងកើតមានបន្ទាប់? តម្រុយពីប្រវត្តិសាស្ត្រ និង ពិធីការ ............................................25

សំនួរញឹកញាប់ អំពីការអនុវត្តន៍ពិធីជ្រមុជទឹក របស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ..................27

សៀវភៅសំរាប់អានផ្សេងទៀត ...............................................................35

អំពីអ្នកនិពន្ធ...........................................................................36



# សេចក្តីផ្តើម

តើយល់យ៉ាងម៉េចដែរចំពោះការដែលក្រុមជំនុំយូណៃធីតមេថូឌីស្ទធ្វើពិធីជ្រមុជទឹក? សេចក្តីផ្តើម នៃ «សេចក្តីសន្យាពិធីជ្រមុជទឹក ១» បង្ហាញពីរបៀបធ្វើ។ គ្រូគង្វាល ឬឌីកិន និយាយ៖

> បងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទ
> តាមរយៈពិធីជ្រមុជទឹកដ៏វិសុទ្ធ
> យើងចូលរួមក្នុងក្រុមជំនុំបរិសុទ្ធរបស់ព្រះគ្រីស្ទ
> យើងត្រូវបានបញ្ចូលក្នុងការសង្គ្រោះដ៏អស្ចារ្យរបស់ព្រះ
> ហើយត្រូវបានប្រគល់ឲ្យនូវកំណើតថ្មីតាមរយៈទឹក និងព្រះវិញ្ញាណ។
> អំណោយរបស់ព្រះទាំងនេះ បានប្រទានមកយើងដោយឥតគិតថ្លៃ។[1]

តាមរយៈពិធីជ្រមុជទឹក យើងកើតជាថ្មីដោយអំណោយទានពីព្រះដោយឥតគិតថ្លៃ ហើយដាក់យើងចូលក្នុងគ្រួសារមួយដែលហៅថា ក្រុមជំនុំ។ ដូចជាគ្រួសារដទៃទៀតដែរ យើងទទួលបានរឿងរ៉ាវជីវិត ក្នុងករណីនេះ រឿងរ៉ាវរបស់យើងមានចែងក្នុងព្រះគម្ពីរ។ រឿងរ៉ាងដែលយើងទទួលបាន មិនមែនគ្រាន់តែជារឿងអតីតកាលទេ តែជារឿងដែលយើងចូលមកក្នុងពេលនេះ ហើយព្រះវិញ្ញាណបរិសុទ្ធផ្តល់កំឡាំងឲ្យយើងរស់នៅជាជីវិតរបស់យើង នៅពេលនេះ និងកន្លែងនេះ។ តាមរយៈពិធីជ្រមុជទឹក យើងក្លាយជាផ្នែកមួយនៃរឿងរ៉ាវនៃព្រះគុណរបស់ព្រះ។

---

[1] *The United Methodist Book of Worship* (Nashville: The United Methodist Publishing House, 1992), 87. (For changes to the ritual mandated by the 2008 General Conference, see “New Membership Vows and Ritual (Revised and Corrected)” www.umcdiscipleship.org/ worship/membership-christian-initiation/new-membership-vows-and-ritual-revised- and-corrected Accessed August 15, 2016.)

ទោះបីយើងនិយាយថា «ទាំងអស់នេះជាអំណោយទាន របស់ព្រះ» វាមិនមានន័យថា យើង គ្មានអ្វីដែលត្រូវធ្វើទៀតទេ ឬយើងគ្មានការរំពឹងទុកនោះទេ។ អំណោយទានមួយដែលល្អ បំផុត ដែលយើងអាចធ្វើបាន សំរាប់អ្នកដែលយើងស្រឡាញ់ គឺជាឱកាសធ្វើអ្វីមួយដែល មានប្រយោជន៍ ឬរកឱកាសច្រើនទៀតសំរាប់ធ្វើការសំខាន់ទាំងនេះ។ ដូច្នេះ នេះគឺស្រេចលើ ព្រះ។ ពេលយើងដឹងដូចនេះហើយ ក្នុងសេចក្តីសន្យានៃពិធីជ្រមុជទឹក ក្រុមជំនុំឲ្យសំនួរបីមក យើង ដើម្បីឲ្យយើងលូតលាស់ក្នុងភាពជាសិស្សរបស់ព្រះគ្រីស្ទ ក្នុងជីវិតរបស់យើង។

> ក្នុងនាមជាក្រុមជំនុំទាំងមូល ខ្ញុំសួរអ្នកថាៈ
> តើអ្នកបដិសេធន៍ចំពោះគ្រប់ទាំងអំណាចនៃអំពើអាក្រក់
> បណ្តេញអំណាចសាតាំងក្នុងពិភពលោក
> និងសារភាពបាបរបស់អ្នកទេ?[2]
>
> តើអ្នកទទួលសិរីភាព និងអំណាចដែលព្រះប្រទានឲ្យអ្នក
> ដើម្បីប្រឆាំងការអាក្រក់ អយុត្តិធម៌ និងការកៀបសង្កត់
> ក្នុងរូបភាពណាក៏ដោយ ដែរឬទេ?[3]
>
> តើអ្នកទទួលព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះ
> ទុកចិត្តដល់ព្រះគុណទ្រង់ទាំងស្រុង
> ហើយសន្យាថានឹងបម្រើទ្រង់ជាព្រះអម្ចាស់របស់អ្នក
> ជាមួយក្រុមជំនុំ ដែលព្រះបានបើក
> ជាមួយមនុស្សគ្រប់វ័យ ជាតិសាសន៍ និងពត៌សម្បុរ ដែរឬទេ?[4]

សំនួរនិមួយៗ អ្នកដែលត្រូវទទួលពិធីជ្រមុជទឹក និង/ឬ អ្នកធានា ត្រូវឆ្លើយ «បាទ/ចាស៎»។ ចម្លើយរបស់យើងមិនមែនសំរាប់តែកម្មវិធីនៅថ្ងៃនេះទេ។ វាជាចម្លើយតំបូង សំរាប់មួយជីវិត ដែលត្រូវធ្វើការជាមួយព្រះគុណ និង ការរីកចំរើនជាមួយព្រះ។ ដូច្នេះហើយបានជាយើងសួរ សំនួរទាំងនេះម្តងទៀតពេលដែលយើងធ្វើពិធីបញ្ជាក់សមាជិកភាព (Confirmation) និងពេល ដែលយើងធ្វើសេចក្តីសន្យាពិធីជ្រមុជទឹក ឡើងវិញ (Reaffirmation) ហើយដូចជាសៀវភៅ វិន័យបានបញ្ជាក់ គ្រប់ពេលដែលអ្នកណាម្នាក់ចូលរួមក្រុមជំនុំដោយការប្រកាសសេចក្តីជំនឿ រួមទាំងអ្នកដែលប្តូរសមាជិកភាពមកពីនិកាយផ្សេងផងដែរ។[5]

---

[2] UMBOW, 88.

[3] Ibid.

[4] Ibid.

[5] សៀវភៅវិន័យយូណៃធីតមេថូឌីស្តឆ្នាំ២០១៦ (Nashville: The United Methodist Publishing House, 2016), paragraph 217, page 157 and paragraph 225, p. 160.

ពេលដែលយើងរៀបចំសម្បត់នេះមួយរយៈមក យើងគួរសួរសំនួជាក់លាក់ ដូចជា «តើអ្នកឃើញ ការអាក្រក់ កើតឡើងនៅកន្លែងណាមួយនៃសហគមន៍របស់អ្នក ហើយតើអ្នកចង់ធ្វើអ្វីដើម្បី ប្រឆាំងនិងការអាក្រក់នេះ?» ការអាក្រក់ភាគច្រើនកើតឡើងដោយពិបាកដឹង ព្រោះវាមិនមែន លេចចេញមកជាបីសាចនោះទេ។ យើងគួរតែសួរ «តើការដែលយើងប្រកាសថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះ ហើយបម្រើទ្រង់ជាព្រះ មានន័យយ៉ាងម៉េចសំរាប់បរិបទតំបន់ របស់អ្នក?» ម្តងទៀត សំនួរទាំងនេះ អាចរចនាជីវិតនៃការយល់ដឹង និងភាពជាសិស្សរបស់ ព្រះគ្រីស្ទ ដោយស្មោះត្រង់។ ខ្ញុំបានពិភាក្សា សម្បត់នៃពិធីជ្រមុជទឹកនេះ និងអត្ថន័យវាជាមួយ សៀវភៅ សម្បត់សមាជិកភាពរបស់យើងក្នុងក្រុមជំនុំ យូណៃធីតមេថូឌីស្ទ ហើយខ្ញុំសូមណែនាំ សៀវភៅនេះដល់លោកអ្នក។[6]

---

[6] Mark W. Stamm, *Our Membership Vows in ¶The United Methodist Church* (Nashville, Tennessee: Discipleship Resources, 2014). អាចទាញយក (download) ពី http://www.umcdiscipleship.org/resources/our-membership-vows-in-the-united-methodist-church Accessed June 13, 2016.



# ពិធីជ្រមុជទឹកៈ ឫសគល់មកពីព្រះគម្ពីរ

ពិធីជ្រមុជទឹកដំបូងរបស់គ្រីស្ទបរិសទ្ធ កើតឡើងនៅថ្ងៃបុណ្យទី៥០។ ពួកសិស្ស «នៅជាមួយគ្នាក្នុងកន្លែងតែមួយ» រងចាំ «សេចក្តីសន្យារបស់ព្រះបិតា» (កិច្ចការ ១៖៤, ២៖១)។ សេចក្តីសន្យានោះបានសំរេច ពេលព្រះវិញ្ញាណបរិសុទ្ធ ចាក់បំពេញពួកគេនៅថ្ងៃនោះ។ ពេញដោយព្រះវិញ្ញាណបរិសុទ្ធ ពួកសិស្សប្រកាសដំណឹងល្អ ជាច្រើនភាសា ដូច្នេះអ្នកដែលមាន វត្តមាននៅទីនោះ «ឮពីអ្វីដែលពួកគេនិយាយពីព្រះចេស្តា និងអំណាចរបស់ព្រះ» (២៖១១)។ ការបើកសម្តែងនេះធ្វើឲ្យអ្នកដែលបានឃើញ និងបានឮ មានការភ្ញាក់ផ្អើល រហូតដល់មានអ្នកខ្លះគិតថាពួកសិស្សស្រវឹង។ លោកពេត្រុស និយាយថា មិនមែនទេ។ ប៉ុន្តែព្រះនៃសាសន៍អ៊ីស្រាអែលកំពុងធ្វើការកណ្តាលចំណោមពួកគេ គឺជាព្រះដែលធ្វើការក្នុងជីវិត ការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ គាត់និយាយថា «ដូច្នេះ សូមឲ្យមនុស្សទាំងអស់ដែលនៅក្នុងផ្ទះសាសន៍អ៊ីស្រាអែល ដឹងយ៉ាងច្បាស់ថា ព្រះបានធ្វើឲ្យទ្រង់ជាព្រះអម្ចាស់ និងព្រះសង្គ្រោះ នេះគឺព្រះយេស៊ូវ ដែលអ្នកបានឆ្កាង» (កិច្ចការ ២៖៣៦)។ អ្នកស្តាប់លោកពេត្រុសសួរថា «តើយើងត្រូវធ្វើដូចម្តេច?» ហើយគាត់បានប្រាប់ពួកគេឲ្យទទួលពិធី ជ្រមុជទឹក (កិច្ចការ ២៖៣៧-៣៨) ។ គាត់ប្រាប់ពួកគេថា

> ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលបានអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ដ្បិតសេចក្តីសន្យានោះ គឺសន្យាដល់អ្នករាល់គ្នា និងកូនចៅអ្នករាល់គ្នា ព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នា ទ្រង់នឹងហៅ។ (កិច្ចការ ២៖៣៨-៣៩)

ការដែលលោកពេត្រុសប្រាប់ឲ្យគ្រប់គ្នាទទួលបុណ្យជ្រមុជទឹក នៅថ្ងៃបុណ្យទី៥០ យើងបានឃើញពីគំរូនៃសកម្មភាពមួយចំនួន ដែលមានចែងក្នុងព្រះគម្ពីរកិច្ចការ។[7]

ដំបូង គឺការហៅឲ្យប្រែចិត្ត។ ពាក្យនេះបកប្រែចេញពីភាសាក្រិច metanoein ដែលមានន័យថា ការផ្លាស់ប្តូរគំនិត និងស្មារតី។ វាមិនមែនគ្រាន់តែជាវិប្បដិសារី ឬការប្រែគំនិតប៉ុណ្ណោះទេ។ វាមានន័យថា យើងត្រូវប្តូរពីជីវិតមួយ ទៅជីវិតមួយទៀត។ យើងអាចពិពណ៌នាវាថា ជាការប្តូរ ១៨០ដឺក្រេ ចេញពីអំពើបាប អំពើអាក្រក់ និងគ្រប់ការដែលជះឥទ្ធិពលអាក្រក់ ដល់ជីវិតឆ្ពោះទៅកាន់នគរព្រះ។

ទីពីរគឺជាការជ្រមុជទឹកដើម្បីអត់ទោសបាប (កិច្ចការ ២៖៣៨)។ យើងមិនដឹងថា តើគេយកទឹកមកធ្វើអីនោះទេ ពាក្យដែលយើងប្រើ ពិធីជ្រមុជទឹក គឺបកប្រែមកពីភាសាក្រិច baptizo ដែលមានន័យថា ជ្រលក់ ឬជ្រមុជ។[8] យ៉ាងហោចណាស់ ពាក្យនេះមានន័យច្រើនចំពោះការប្រើប្រាស់ទឹក។ ប្រភពបុរាណមួយទៀតនិយាយថា ការជ្រមុជទឹកត្រូវធ្វើក្នុងទឹកដែលត្រជាក់ និង « ទឹករស់» ដែលជាទឹកហូរ តែបើសិនជាមិនអាចរកបានទេ ទឹកផ្សេងទៀតអាចប្រើបាន។ ក្នុងបរិបទសត្តវត្សទី១ និងទី ២ ការប្រើទឹកអាចប្រើបានជាច្រើនវិធី។[9]

ទីបីគឺជាការសន្យាថា អ្នកដែលទទួលពិធីជ្រមុជទឹក នឹង «ទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ»។ សេចក្តីសន្យានោះមិនមែនសំរាប់អ្នកដែលមានវត្តមានទេ ប៉ុន្តែវាបន្តដល់ កូនៗ និងអ្នកនៅជិតឆ្ងាយ និងអស់អ្នកដែលព្រះអម្ចាស់ត្រាស់ហៅ» (កិច្ចការ ២៖៣៨-៣៩) ពេលយើងអានបន្តទៀតក្នុងព្រះគម្ពីរកិច្ចការ ជួនកាលព្រះវិញ្ញាណបានប្រទានមក មុនពេល ពិធីជ្រមុជទឹកទៀត (កិច្ចការ ១០៖៤៤-៤៨) ហើយជួនកាលបន្ទាប់ពីពិធីជ្រមុជទឹក (កិច្ចការ ១៩៖១-៧)។ យើងមិនអាចដឹងថាព្រះវិញ្ញាណបរិសុទ្ធ នឹងធ្វើការបែបណាទេ ព្រោះទ្រង់មាន សិរីភាព។ ដូច្នេះសូមយើងនិយាយថា ពិធីជ្រមុជទឹក ដាក់យើងចូលក្នុងសហគមន៍មួយ ដែលព្រះវិញ្ញាណគង់នៅ។

តើយើងគិតយ៉ាងម៉េចចំពោះសេចក្តីសន្យាចំពោះកូនក្មេង? នេះជាភាសានៃសេចក្តីសន្យា។ ចំពោះសាសន៍ហេព្រើរ ការយល់ថា សន្យាចំពោះអ្នកដឹកនាំក្នុងគ្រួសារ តែងតែមានន័យចំពោះកូនក្មេងផងដែរ (សូមមើល លោកុប្បត្តិ ១២៖១-៣, ១៧៖១-៤)។ នេះគឺជាគ្រឹះផ្នែកទេវសាស្រ្ត ដែលមិនគ្រាន់តែអនុញ្ញាតិអោយធ្វើពិធីជ្រមុជសំរាប់ក្មេងៗទេ គឺរំពឹងទុកឲ្យធ្វើតែម្តង។ នេះ

---

[7] See also Acts 8:26-40, 9:10-19, 10:1-48, 16:11-15, and 16:25-34.

[8] Arndt, William F. and F. Wilbur Gingrich, *A Greek-English Lexicon of the New Testament and Other Early Christian Literature*. (Chicago and London: The University of Chicago Press, 1957, 1979), 131.

[9] ការបង្រៀនរបស់សាវ័ក្សទាំង១២ ដែលទូទៅគេហៅថា The Didache," Cyril C. Richardson, translator and editor, Early Christian Fathers (New York: Collier Books, 1970), 7:1-4, p. 174.

មិនមែនទេវសាស្ត្រថ្មីទេ វាត្រូវបានមនុស្សទទួលស្គាល់ និងអនុវត្តតាំងពីសម័យ លោកអាប្រាហាំ ។ ក្នុងពេលដែលព្រះគម្ពីរសញ្ញាថ្មីមិនមានចែងពីពិធីជ្រមុជទឹកសំរាប់ក្មេងៗ ការសន្មត់នៃសេចក្ដីសន្យាជាសាក្សីនៃពិធីជ្រមុជជាគ្រួសារ ដែលមេគ្រួសារប្រែចិត្ត ហើយទទួលពិធីជ្រមុជដល់គ្រប់គ្នានៅក្នុងផ្ទះ ដែលរាប់ទាំងកូនក្មេងផងដែរ (កិច្ចការ ១៦៖១១-១៥, ២៥-៣៤)។ ក្រុមគ្រីស្ទបរិសទ្ធខ្លះ មិនយល់ស្របចំពោះការបកស្រាយដែលខ្ញុំបានពន្យល់ ប៉ុន្តែដើមសតវត្សទី៣ មានពិធីជ្រមុជទឹកដល់កុមាររួចហើយ[10] មានន័យថា យ៉ាងហោចណាស់ មានគ្រីស្ទបរិសទ្ធពីដើមខ្លះ ក៏យល់ដូចខ្ញុំដែរ។ ប៉ុន្តែ វាគ្មានវិធីណាមកបង្ហាញថា គ្រីស្ទបរិសទ្ធ កាលពីសតវត្សទី១ បានធ្វើពិធីជ្រមុជដល់កូនក្មេង ឬក៏អត់នោះទេ។

ដូចជាពួកយើងដែលបន្តយល់ដឹងពីបន្ទាល់របស់សាវក្ស និងគ្រីស្ទបរិសទ្ធដំបូង (អេភេសូ ២៖២០) ទាក់ទងទៅនិងការអនុវត្តន៍វិធីវិសុទ្ធ ដូចជាថាតើយើងគួរជ្រមុជទឹកកូនក្មេងឬអត់ ដែលនេះជាការងាររបស់ព្រះវិហារ ហើយព្រះវិហារក្នុងនិកាយផ្សេងគ្នា យល់ផ្សេងគ្នាពីការនេះ។ ដើម្បីឲ្យយល់ច្បាស់ គ្រូគង្វាលមួយៗ ឬក្រុមជំនុំម្នាក់ៗ មិនបានសំរេចចិត្តចំពោះគំនិតណាមួយទេ។ និកាយជាអ្នកកំណត់។ ចំពោះនិកាយរបស់យើង យើងបានបន្តធ្វើពិធីជ្រមុជ ដល់ក្មេងៗ ហើយដល់អស់អ្នកណាដែលមិនអាចឆ្លើយសំនួរដោយខ្លួនឯងបាន ហើយអាច ទទួលបានប្រយោជន៍ពីការនេះ លើសពីអ្វីដែលយើងស្មានដល់។

ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ ក៏ដូចជាក្រុមជំនុំអន្តរនិកាយ វាអាចជួយយើងបាន ពេលយើងទទួលមនុស្សគ្រប់គ្នា ដែលងើបឡើងពីទឹកវិញ ទោះជាគេអាយុ៥០ថ្ងៃ ឬ ៥០ឆ្នាំ ជាក្មេងក្នុងព្រះគ្រីស្ទ ទើបកើតជាថ្មី ហើយត្រូវការសហគមន៍ដើម្បីជួយគាំទ្រ និងការពារគេ (សូមមើល យូហាន ៣៖១-៧). ផ្ទុយទៅវិញ និកាយ Anabaptist និង បាបទីស្ទ ជួយអោយយើងដឹងថា ភាពពេញវ័យជាគ្រីស្ទបរិសទ្ធ គឺជាគោលដៅក្នុងការអនុវត្តន៍ពិធីជ្រមុជទឹក។ (យើងយល់ស្របជាមួយគេក្នុងគោលដៅនេះ។ បើសិនជាអ្នកចង់យល់បន្ថែមពីការអនុវត្តន៍ពិធីជ្រមុជទឹក កុមារ សូមអានសៀវភៅ Baptism, *Understanding God's Gift* by L. Edward and Sara Webb Phillips.[11])

ចុងបញ្ចប់នៃរឿងថ្ងៃទី៥០ គឺល្អមែនទែន។ «ហើយនៅថ្ងៃដដែលនោះ មានប្រហែលជា៣ពាន់នាក់ថែមកើនឡើងទៀត។» (កិច្ចការ ២៖៤២)។ ពេលខ្ញុំប្រាប់រឿងនេះដល់សិស្សរបស់ខ្ញុំ ខ្ញុំតែងតែឈប់បន្តិច ហើយនិយាយថា «ហើយពួកគេត្រលប់ទៅផ្ទះ ហើយនិយាយថា នេះពិតជា

---

[10] Ibid., *The Apostolic Tradition,* 112. See references to the baptism of "the small children." See also Tertullian's Homily on Baptism, Ernest Evans, translator and editor (London: SPCK, 1964), 18, pp. 37 and 39. លោក Tertullian ប្រឆាំងនឹងការជ្រមុជទឹកដល់កុមារ តែការប្រឆាំងរបស់គាត់នេះ បង្ហាញឲ្យឃើញថា មានការជ្រមុជទឹកដល់កុមារ។

[11] L. Edward Phillips and Sara Webb Phillips, *Baptism, Understanding God's Gift.* (Nashville, Tennessee: Discipleship Resources, 2011).

បទពិសោធន៍នៃការផ្លាស់ប្តូរដ៏អស្ចារ្យ» ពេលគេផ្តោតអារម្មណ៍ គេនឹងប្រកែកថា «មិនមានរឿងអញ្ចឹងកើតឡើងទេ» ហើយគេនិយាយត្រូវ។ គ្រីស្ទបរិសទ្ធ ដំបូងនោះ ក្លាយទៅជាសហគមន៍ថ្មីមួយ ដែល «ព្យាយាមក្នុងសេចក្តីបង្រៀនរបស់ពួកសាវ័ក ហើយក្នុងសេចក្តីប្រកបគ្នា ព្រមទាំងកាច់នំបុ័ង និងសេចក្តីអធិស្ឋានផង» (កិច្ចការ ២៖៤២)។ សហគមន៍របស់ពួកគេ ជាសហគមន៍ដែលព្រះវិញ្ញាណបរិសុទ្ធបើកសម្តែង។ គេថែរក្សាគ្នា ចូលរួមជាមួយគ្នាក្នុងការ ជាច្រើន ហើយការចែកចាយគ្នានេះ បានហូរហៀរ នាំឲ្យអ្នកដទៃ បានចូលរួមក្នុងការ ប្រកបគ្នានេះដែរ។ ផ្នែកផ្សេងទៀតក្នុងព្រះគម្ពីរកិច្ចការ រៀបរាប់ពីរឿងនៃការហូរហៀរនេះ និងព្រះគុណរបស់ព្រះ ដែលបានទទួលក្នុងពិធីជ្រមុជទឹក។ អ្នកខ្លះយល់ថា រឿងនេះទាក់ទង និងបេសកកម្ម ដែលយើងនឹងស្វែងយល់នៅវគ្គក្រោយ។



# ពិធីជ្រមុជទឹកៈ វិធីនៃសេចក្ដីសង្គ្រោះ និង ការមើលទៅមុខផ្នែកបេសកកម្ម

មេថូឌីស្ទ បានពិភាក្សាពីពិធីជ្រមុជទឹក ជាយូរមកហើយ ដែលយើងនិងគ្រីស្ទបរិសទ្ធជាច្រើនទៀត ហៅថា «លំដាប់នៃសេចក្ដីសង្គ្រោះ»។ ឬសដែលទាក់ទងរវាងពិធីជ្រមុជទឹក និងសេចក្ដីសង្គ្រោះ មាននៅក្នុងបទគម្ពីរ ដែលយើងបានពិភាក្សា ក្នុងនោះលោកពេត្រុស និយាយទៅកាន់អ្នកដែលចង់ទទួលពិធីជ្រមុជទឹកថា «ចូរឲ្យអ្នករាល់គ្នាបានសង្គ្រោះរួចពីពូជដំណវៀចនេះ។» (កិច្ចការ ២៖៤០)។ ដូច្នេះមានន័យថា គ្រីស្ទបរិសទ្ធពីដំបូងជឿថា ពិធីជ្រមុជទឹក គឺជារឿងពាក់ពន្ធ័ទៅនិងការសង្គ្រោះរបស់ព្រះ។

លោកវេស្លី បានពន្យល់ពី លំដាប់នៃសេចក្ដីសង្គ្រោះ ថាជាព្រះគុណរបស់ព្រះ ដែលនឹងសង្គ្រោះយើងដោយបីរបៀប។ ទីមួយគឺ «ព្រះគុណដើម» ជាព្រះគុណដែលនាំយើងចូលជិតព្រះ ហើយព្រះគុណនេះមាននៅក្នុងយើងមុនពេលដែលយើងដឹងទៀត។ ទីពីរគឺ «ព្រះគុណរាប់ជាបរិសុទ្ធ» ការងាររបស់ព្រះដែលធ្វើឲ្យយើងមានទំនាក់ទំនងជាមួយព្រះ ទទួលបានការអត់ទោសនៃអំពើបាប។ ទីបី គឺ «ព្រះគុណឆ្ពោះទៅរកភាពបរិសុទ្ធ» ដែលជាការងាររបស់ ព្រះដែលធ្វើឲ្យយើងបានបរិសុទ្ធ ដែលធ្វើឲ្យយើងកាន់តែស្រឡាញ់ព្រះ អ្នកដទៃ និងអស់អ្នកដែលទ្រង់បង្កើត។ អ្នកខ្លះនិយាយថា ពិធីជ្រមុជទឹកក្មេងៗ គឺជាពិធីវិសុទ្ធ ដែលចេញពីព្រះគុណដើម។ ប៉ុន្តែ ការបកស្រាយព្រះគម្ពីរតាមលោកវេស្លី ក៏បានពន្យល់យើង ឲ្យឃើញថា ពិធីនេះក៏ទាក់ទង ព្រះគុណរាប់ជាបរិសុទ្ធ (លៀងយើងឲ្យរួចពីបាប) ហើយ វាក៏ហូរទៅកាន់ ព្រះគុណឆ្ពោះទៅរកភាពបរិសុទ្ធ។ ដូច្នេះ យើងធ្វើបានល្អ ក្នុងការឃើញព្រះគុណសង្គ្រោះរបស់ព្រះ មិនមែនគ្រាន់តែជាខ្សែរត្រង់ចេញពីព្រះគុណដើម ព្រះគុណរាប់ជាសុច្ចរិត និងព្រះគុណឆ្ពោះទៅរកភាពបរិសុទ្ធទេ តែវាជាខ្សែរកោង និងមានឥទ្ធិពល។ ទោះខ្ញុំជាគ្រីស្ទបរិសទ្ធអស់រយៈពេលជាច្រើនឆ្នាំក៏ដោយ ព្រះបន្តនាំខ្ញុំចូលទៅកាន់ការប្រកបជាមួយទ្រង់ យ៉ាងជិតស្និទ្ធ និងការតាំងចិត្តចំពោះបេសកកម្ម

របស់ព្រះ និងបន្តប្រាប់ខ្ញុំពីអំពើបាប និងការអត់ទោស។ ទាំងព្រះគុណរាប់ជាបរិសុទ្ធ និង ព្រះគុណឆ្ពោះទៅរកភាពបរិសុទ្ធ មានវត្តមានក្នុងពិធីជ្រមុជទឹក ហើយការនេះនិងបន្តរហូតដល់ក្លាយជាគ្រីស្ទបរិសទ្ធ ពេញវ័យ។

ដូច្នេះ ក្នុងនាមជាយូណៃធីតមេថូឌីស្ទ ដែលយល់ពីទំនាក់ទំនងរវាងពិធីជ្រមុជទឹក និងការសង្គ្រោះ យើងដឹងថា ទេវវិទ្យារបស់យើង មិនបាននាំឲ្យយើងនិយាយថា ពិធីជ្រមុជទឹកជាភស្តុតាងថា «អ្នកណាម្នាក់នឹងទៅឋានសួគ៌ ពេលគេស្លាប់» នោះទេ។ លោកចន វេស្លី ចាប់ផ្តើមបទអធិប្បាយរបស់គាត់ដែលមានចំណងជើងថា «វិធីនៃសេចក្តីសង្គ្រោះតាមព្រះគម្ពីរ» ដោយនិយាយថា៖

> ដំបូង សូមយើងសួរថា តើអ្វីទៅជាការសង្គ្រោះ? ការសង្គ្រោះ ដែលយើងនិយាយ ជាច្រើនដង មិនមែនជាអ្វីដែលយើងយល់ថាជាការទៅឋានសួគ៌ ឬការសប្បាយអស់កល្បជានិច្ចនោះទេ។ មិនមែនមានន័យថា ព្រលឹងទៅឋានសួគ៌ ឬពាក្យរបស់ព្រះអម្ចាស់ «ដើមទ្រូងលោកអាប្រាហាំ»។ វាមិនមែនជាព្រះពរដែលមានបន្ទាប់ពីការស្លាប់ ឬនៅឋានខាងមុខ។ ពាក្យនេះឆ្លើយគ្រប់សំនួរ៖ «អ្នកត្រូវបានសង្គ្រោះ»។ វាមិនមែនជាអ្វីដែលនៅឆ្ងាយទេ។ វាគឺជារឿងបច្ចុប្បន្ន ជាព្រះពរ តាមរយៈសេចក្តីមេត្តាករុណារបស់ព្រះ ដែលអ្នកមាន។ ពាក្យនេះអាចនិយាយម្យ៉ាងទៀតថា «អ្នកត្រូវបានសង្គ្រោះរួចហើយ» ដូច្នេះសេចក្តីសង្គ្រោះដែលយើងនិយាយនៅពេលនេះ គឺសំដៅលើការងារ ទាំងអស់ដែលព្រះអម្ចាស់បានធ្វើតាំងពីដំបូងដែលព្រះបានប្រទានព្រះគុណ រហូតដល់យើងបានឃើញសិរីរុងរឿងទ្រង់។[12]

ការសង្គ្រោះរបស់ព្រះ ដែលលោកវេស្លីនិយាយ គឺជាអ្វីដែលព្រះបានធ្វើដើម្បីសង្គ្រោះយើងចាប់ផ្តើមពីជីវិតនេះទៅ។ យោងតាមលោកវេស្លី ពិធីជ្រមុជទឹក គឺជា «ឧបករណ៍សម័ញ្ញ នៃការរាប់ជាសុច្ចរិត»[13] ពាក្យថា «សម័ញ្ញ» មានន័យថា «ធម្មតា» ឬ «ជារឿយៗ»។ វាមានន័យសំរាប់យើងថា ពិធីជ្រមុជទឹក គឺជាកន្លែងដែល ការរាប់ជាសុច្ចរិត ចាប់ផ្តើមសំរាប់យើងទាំង អស់គ្នា ហើយវាគឺជាវិធីប្រាកដមួយ នៃការចាប់ផ្តើមការរាប់ជាសុច្ចរិតរបស់ព្រះ (និងការញែកជាបរិសុទ្ធ)។ វាក៏មិនមែនមានន័យថា ព្រះមិនអាចធ្វើការតាមវិធីផ្សេងទៀតដែរ។

ប្រពៃណីវេស្លីយល់ថា ពិធីជ្រមុជទឹក គឺជាវិធីសម័ញ្ញបំផុត ដែលព្រះផ្តល់អំណាចដល់យើងអោយចូលរួមក្នុងជីវិត និងបេសកកម្មរបស់ទ្រង់ ទាំងក្នុងយើង និងតាមរយៈយើង នៅទីនេះ និងគ្រប់ការទាំងអស់។ កិច្ចការជំពូកពីរ បានចង្អុលប្រាប់ពីការនេះ ក៏ដូចជាការប្រកាសរបស់ យើង

---

[12] John Wesley, "The Scripture Way of Salvation" http://www.umcmission.org/Find-Resources/John-Wesley-Sermons/Sermon-43-The-Scripture-Way-of-Salvation. Accessed August 24, 2016.

[13] John Wesley, "On Baptism," in John Wesley, edited by Albert C. Outler (New York: Oxford University Press, 1964), II.1, p. 321. Emphasis added.

ក្នុងពិធីជ្រមុជទឹកដែរ «យើងចូលរួមក្នុងកិច្ចការសង្គ្រោះរបស់ព្រះអម្ចាស់»[14] ពិធីលៀងព្រះអម្ចាស់នាំឲ្យយើងចាប់ផ្ដើមផ្លូវមួយនៃការក្លាយទៅជាផ្នែកមួយនៃបេសកកម្មរបស់ព្រះក្នុងពិភពលោក។

ចាប់ផ្ដើមពីពិធីជ្រមុជទឹករបស់គេ អ្នកដែលទទួលបានពិធីជ្រមុជទឹក ចាប់ផ្ដើមចូលទៅយ៉ាងជ្រៅក្នុងព្រះគុណឆ្ពោះទៅភាពបរិសុទ្ធ ក្នុងសហគមន៍ ជាមួយក្រុមជំនុំ ដែលយើងត្រូវបានត្រាស់ហៅឲ្យប្រឆាំងនិងអំពើអាក្រក់ និងមិនធ្វើអាក្រក់។[15] បទអធិប្បាយ និងពិធីបរិសុទ្ធ ឲ្យយើងអាចបំរើព្រះអម្ចាស់ និងធ្វើគ្រប់ទាំងការល្អ។[16] យើងយកពិធីជ្រមុជទឹករបស់យើង ដើម្បីអធិស្ឋានសំរាប់ពិភពលោក ហើយបន្តរស់នៅតាមព្រះហរទ័យរបស់ព្រះកាន់តែជ្រៅ។ ជីវិតរស់នៅជាមួយព្រះគ្រីស្ទ ចាប់ផ្ដើមពីពិធីជ្រមុជទឹក។ យើងដឹងថា គោលបំណងនៃជីវិត គឺជាប់ទាក់ទងទៅនិងការដែលយើងបំរើអ្នកដទៃ។ ក្នុងពិធីជ្រមុជទឹក យើងដើរចូលក្នុងទឹករស់ ហើយក្នុងទឹករស់នោះឯងដែលយើងទទួលបានរស់ជាតិនៃស្ថានសួគ៌។

---

[14] *UMBOW,* 87.

[15] "The General Rules of the Methodist Church," *The Book of Discipline of The United Methodist Church,* 2016 (Nashville: The United Methodist Publishing House, 2016), paragraph 104, pp. 78-79.

[16] Ibid., p. 79.



# ឈានជើងចូលក្នុងទឹករស់ៈ ការអនុវត្តន៍ទំនាមទំលាប់ នៃពិធីជ្រមុជទឹក

ព្រះយេស៊ូវមានបន្ទូលប្រាប់ស្ត្រីសាសន៍សាម៉ារីថា ទ្រង់អាចឲ្យ «ទឹករស់» ដល់នាង។ ទ្រង់មានបន្ទូលថា «អ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ» (យ៉ូហាន ៤៖១៣)។ ជាងនេះទៀត ការដែលយើងចូលក្នុងគ្រួសារទឹករស់ យើងក្លាយទៅជាព្រះពរសំរាប់ពិភពលោក និងការចូលរួមក្នុង «ទឹកដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច» (យ៉ូហាន ៤៖១៤)។ ការដែលក្លាយទៅជាប្រភពនៃព្រះគុណ ធ្វើឲ្យយើងស្កប់ចិត្ត ដោយសារព្រះបង្កើតយើងមកដើម្បី «ឲ្យខ្លួនយើងដល់អ្នកដទៃ»[17] ការបរិច្ចាកជីវិតខ្លួនយើង គឺនៅក្នុងដួងចិត្តនៃជីវិតព្រះត្រ័យឯកក្នុងនាមដែលយើងធ្វើពិធីជ្រមុជទឹក។ ពេលនោះយើងជាមនុស្សពេញលេញ ហើយនៅជិតព្រះជាទីបំផុត ពេលដែលយើងឲ្យ ដោយក្តីស្រឡាញ់។

តើយើងធ្វើការជាមួយព្រះយ៉ាងម៉េច ដើម្បីធ្វើឲ្យមនុស្សរស់ក្នុងជីវិតបែបនេះ និងជាពិសេសទៀត តើយើងបង្ហាញគោលតំលៃទាំងនេះក្នុងពិធីជ្រមុជទឹក យ៉ាងដូចម្តេច?

យើងចាប់ផ្តើមដោយ ធ្វើតារាងមួយ។

---

[17] សូមមើលការអធិស្ឋានបន្ទាប់ពីពិធីលៀងព្រះអម្ចាស់, “A Service of Word and Table I,” *UMBOW*, 39.

# តារាងរបស់អ្នកៈ ការរៀបចំសំរាប់ពិធីជ្រមុជទឹក ដោយសំឡឹងមើលគោលដៅខាងមុខ

អ្នកនាំមុខកម្មវិធីល្អ ត្រូវតែផ្ដោតការយកចិត្តទុកដាក់ចំពោះ ពិធីការ និងគោលដៅដែលវានាំយើងទៅ។[18] គោលដៅសំរាប់ការអនុវត្តរបស់គ្រីស្ទបរិសទ្ធទាំងអស់គឺ ស្រឡាញ់ព្រះ និងអ្នកជិតខាង។[19] គោលបំណងនៃពិធីជ្រមុជទឹក គឺការចូលក្នុងសេចក្ដីស្រឡាញ់ និងការសង្គ្រោះរបស់ព្រះត្រ័យឯក ដែលបានបើកសម្ដែងមកយើងរាល់គ្នា តាមរយៈព្រះយេស៊ូវ។ ពិធីជ្រមុជទឹកមានចលនាជាច្រើន។ ដើម្បីដឹកនាំដោយសេចក្ដីស្រឡាញ់ វាទាមទាឲ្យមានជាការបង្ហាញ ដែលអ្នកដឹកនាំល្អត្រូវធ្វើតារាង។ ប្រហែលមិនមែនយើងគ្រប់គ្នាយល់ស្របថា ការធ្វើតារាង វាល្អនោះទេ តែយើងត្រូវការវា។

ជាអ្នកដឹកនាំកម្មវិធី ហើយជាអ្នកសិក្សាពីកីឡា baseball[20] ខ្ញុំគិតថាតារាងសំខាន់ណាស់ ប្រហែលវាមិនរំភើបដូចថ្ងៃបើកឆាកដំបូងទេ តែវាសំខាន់។ ថ្ងៃបើកឆាកនឹងរញ៉េរញ៉ៃ បើអត់មានតារាង។ តើអ្នកយាមរថយន្ត អ្នកទទួលភ្ញៀវ ពេទ្យបថម បានហ្វឹកហាត់ឬនៅ? តើចំណីអាហារសំរាប់លក់ដូចជាសណ្ដែកដី នំប័ុងប៉ាតេ និងក្រដាសកម្មវិធី មានក្នុងស្តុកឬនៅ? ដូចគ្នានេះដែរ សេចក្ដីអំណរនឹងគ្មានទេ បើថ្ងៃបើកឆាកដំបូង មិនត្រូវបានគេយកចិត្តទុកដាក់ឲ្យហ្មត់ចត់។

ខាងក្រោមនេះជាតារាងរបស់ខ្ញុំសំរាប់ពិធីជ្រមុជទឹកៈ
- អ្នកទទួលពិធីជ្រមុជម្នាក់ ឬច្រើន, គ្រូគង្វាល, និងក្រុមជំនុំ[21]
- អ្នកធានា[22]
- សមាជិកក្រុមជំនុំម្នាក់ ជាអ្នកណែនាំអ្នកទទួលពិធីជ្រមុជទឹក[23]
- កន្លែងប្រជុំ... ពែងទឹក (ឬប្រភព«ទឹករស់») និងកន្លែងដែលក្រុមជំនុំអាចឈរជុំវិញថូទឹក។ គួរគិតពីឃ្លាដែលក្រុមជំនុំអាចឆ្លើយស្របគ្នា ដើម្បីឲ្យពួកគេចូលរួមដែរ។

---

[18] See Romans 10:4.

[19] See John Wesley, "The Means of Grace," *The Works of John Wesley, Volume I*, edited by Albert Outler (Nashville: Abingdon Press, 1984), I.2 (p. 378), II.2 (p. 381).

[20] ខ្ញុំជាសមាជិកនៃ North American Academy of Liturgy និង Society for American Baseball Research.

[21] "Service of the Baptismal Covenant," paragraphs 1 & 2, *UMBOW*, p. 87.

[22] Ibid., paragraphs 5 & 7, 88.

[23] Ibid., paragraph 2, 87.

- ទឹក កាន់តែច្រើន កាន់តែល្អ។ យើងប្រហែលត្រូវការថូសំរាប់ចាក់ទឹក (ចូលក្នុងពែង ឬចាក់លើអ្នកដែលទទួលពិធីជ្រមុជទឹក។)[24]
- ពិធីការនៃពិធីជ្រមុជទឹក ឬពិធីការដែលបានយល់ស្របគ្នា[25] សំរាប់យូណៃធីតមេថូឌីស្ទ សូមប្រើកម្មវិធីសំរាប់សេចក្ដីសន្យាជ្រមុជទឹក[26] ធ្វើដូច្នេះដើម្បីឲ្យពេលដែល វិធីបានបញ្ចប់ទៅ អ្នករាល់គ្នាដឹងច្បាស់ថា កម្មវិធីជ្រមុជទឹក ទើបបានបញ្ចប់។

បន្ថែមលើនេះទៀត យើងអាចប្រើៈ
- អ្នកជំនួយផ្សេងទៀតដូចជាឌីកិន អ្នកភ្លេង និង អ្នកនាំភ្លើងទាន
- ប្រេងសំរាប់ឲ្យពរដល់អ្នកដែលទើបទទួលពិធីជ្រមុជទឹក និងពែងសមរម្យសំរាប់ដាក់ប្រេងនោះ។[27]
- កន្សែង ព្រោះអ្នកខ្លះនឹងទទឹក ហើយអ្នកចាត់ចែងព្រះវិហារ នឹងមិនបារម្មណ៍ថា នឹងមានការខូចខាតអាគារដោយសារ អ្នកប្រើទឹកច្រើនពេក
- ទាន សញ្ញាប័ត្រ និងអំណោយតូចៗ សំរាប់ជូនដល់អ្នកដែលទើបទទួលពិធីជ្រមុជ និងអ្នកធានា។ (ឧទាហរណ៍ ក្នុងក្រុមជំនុំមួយដែលខ្ញុំជាគ្រូគង្វាល ក្រុមស្ត្រីធ្វើភួយ ដើម្បីជូនដល់ឪពុកម្ដាយកុមារដែលទទួលពិធីជ្រមុជទឹក។)[28]

បន្ថែមលើការរៀបចំការទាំងប៉ុន្មានដែលទាក់ទងនិងពិធីការនៃពិធីជ្រមុជទឹក ក្រុមជំនុំយើងត្រូវការការណែនាំមុនពេលធ្វើពិធីនេះ។[29] ដំណើរការរៀបចំពិធីជ្រមុជទឹក វាមិនមែនគ្រាន់តែជាការបង្រៀនពីគោលលិទ្ធិ និងការសមកម្មវិធី។ មុនពេលធ្វើពិធីជ្រមុជទឹក គួរមានការបង្រៀនដល់អ្នកធានា អំពីសម្បត់នៃពិធីជ្រមុជទឹក និងការដែលពិធីនេះ បង្ហាញយើងពីព្រះគុណ និងគោលការណ៍ជីវិតដែលព្រះបានត្រាស់ហៅយើងឲ្យចូលក្នុងសហគមន៍នេះ។ វាក៏គួរមានសេចក្ដីអធិស្ឋាន ជាមួយអ្នកត្រូវទទួលពិធីជ្រមុជទឹក និងអ្នកធានា ក្នុងពេលប្រជុំ រៀបចំកម្មវិធី និងសេចក្ដីអធិស្ឋាន របស់ក្រុមជំនុំក្នុងកម្មវិធីថ្វាយបង្គំ ដែលជាពេលសំរាប់ការលើកទឹកចិត្ត និង

---

[24] Ibid., paragraph 10, 90-91.

[25] ដូចខ្ញុំបាននិយាយជាមួយកូនសិស្សដែលមានប្រវត្តិមកពីក្រុមជំនុំគ្រប់និកាយ ទោះបីជាក្រុមជំនុំរបស់គេមានទំលាប់ផ្សេងៗ ហើយទោះជាពិធីការទាំងនោះមិនមានសរសេរជាសៀវភៅ។ ក្នុងករណីនោះ គេមិនអាចដឹងថាមានដែនកំណត់ត្រង់ណាទេ បើគេមិនទាន់ដើរហួសនោះ។

[26] *Discipline*, 2016. paragraph 1113.3. “The ritual of the Church is that contained in *The United Methodist Hymnal* (1989), *The United Methodist Book of Worship* (1992), *Mil Voces Para Celebrar: Himnario Metodista* (1996), and *Come Let Us Worship: The Korean-English United Methodist Hymnal* (2000).”

[27] “Service of the Baptismal Covenant,” paragraph 11a, 91.

[28] Ibid., paragraph 11c & d, *UMBOW*, 91.

[29] *Discipline*, 2016, paragraph 226.1.

ជួយគាំទ្រគ្នា។ យើងធ្វើការទាំងនេះដើម្បីយើងអាចចូលរួមជាមួយព្រះ គុណរបស់ព្រះ ហើយយើងមិនជ្រៀតជ្រែកការងាររបស់ព្រះវិញ្ញាណ។ ការរពឹងទុក និងការលើកទឹកចិត្ត មិនបានបន្ថែមទៅលើព្រះគុណព្រះទេ។ គោលការណ៍ទាំងនេះគឺជាការបញ្ញាក់ពីព្រះគុណរបស់ព្រះដែលជាផ្នែកមួយដែលព្រះកំពុងធ្វើការជាមួយសហគមន៍នៃអ្នកដែល បានទទួលពិធីជ្រមុជ។ យើងជឿថាព្រះគុណគឺជាអាចកំបាំងមួយ។ វាជ្រៅជាងការយល់ឃើញរបស់យើង។ យើងក៏ជឿថា ព្រះគុណមានទំរង់ជាក់លាក់មួយ។ សំរាប់យើង ទំរង់នេះ បានពិពណ៌នាក្នុងសម្បត់នៃពិធីជ្រមុជទឹក និងក្នុងច្បាប់ទូទៅ ដែលនាំយើងឲ្យរស់នៅក្នុងជីវិតដែលជៀសវាងអំពើអាក្រក់ ធ្វើការល្អតាមដែលយើងអាចធ្វើបាន និងធ្វើគ្រប់វិធីនៃព្រះគុណ។[30]

[30] "The General Rules of the Methodist Church," *Discipline* 2016, para. 104, pp. 77-80.



# ការបង្កើតក្តីស្រម៉ៃនៃពិធីវិសុទ្ធៈ ទំនាមទំលាប់នៃការប្រើទឹក

ក្នុងថ្ងៃពិធីជ្រមុជទឹក ក្រុមជំនុំប្រជុំគ្នា ហើយអញ្ជើញអ្នកដែលត្រូវទទួលពិធីជ្រមុជទឹក និងអ្នកធានា មកខាងមុខ។ ក្រុមជំនុំសួរពួកគេ ដោយយោងលើសំនួរនៃពិធីជ្រមុជដែលបានបង្ហាញខាងដើម។ អ្នកធានា និងអ្នកដែលត្រូវទទួលពិធីជ្រមុជ និងក្រុមជំនុំ ប្រកាសសេចក្តីជំនឿរបស់ពួកសាវក្យ។ រួចធ្វើការអរព្រះគុណចំពោះទឹក និងការធ្វើពិធីជ្រមុជទឹក។[31] ពេលក្រុមជំនុំប្រជុំគ្នាក្នុងពិធីជ្រមុជទឹក ហើយធ្វើពិធីនេះដោយទឹក ដែលមានគ្រូគង្វាលជាអ្នកដឹកនាំ «ក្នុងព្រះនាមព្រះវបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ»[32] នោះយើងបានធ្វើពិធីជ្រមុជទឹក ដែលទទួលស្គាល់ដោយក្រុមជំនុំយូណៃធីតមេថូឌីស្ទ និងគ្រីស្ទបរិសទ្ធភាគច្រើនក្នុងពិភពលោក។ ដូច្នេះខ្ញុំស្នើរឲ្យប្រើទឹកច្រើន[33] ក៏សូមជម្រាបផងដែរថា ខ្ញុំមិនមែនជានិកាយបាបទីស្ទទេ។ ពិតណាស់ បងប្អូនកាតូលិករបស់យើង ឥឡូវសង់អាងជ្រមុជទឹកច្រើន ក្នុងកន្លែងថ្វាយបង្គំ ហើយក៏មានការលើកទឹកចិត្តឲ្យសង់ពេលសង់ព្រះវិហារថ្មីៗ។ ស្រដៀងគ្នានេះដែរ ខ្ញុំក៏មិនបាននិយាយថា មេថូឌីស្ទ ក្លាយជាកាតូលិកដែរ។ ពេលខ្ញុំស្នើរឲ្យ មានការប្រើទឹកច្រើនក្នុងពិធីជ្រមុជទឹក ខ្ញុំចង់ឲ្យមានការស្រម៉ៃយ៉ាងជ្រៅនៃពិធីវិសុទ្ធ ក្នុងនិកាយមេថូឌីស្ទយើង។

---

[31] *UMBOW*, 87-91.

[32] យូណៃធីតមេថូឌីស្ទ មិនអនុញ្ញាតិឲ្យប្រើរូបមន្តពិធីជ្រមុជទឹកណាផ្សេងទៀតទេ។

[33] សូមមើលការពិភាក្សារបស់ខ្ញុំក្នុងសៀវភៅ Sacraments and Discipleship, Understanding Baptism and the Lord's Supper in a United Methodist Context (Ashland, TN: OSL Publications, 2013, originally published by Discipleship Resources in 2001), 63-66.

យើងអាចពិចារណាធ្វើឲ្យពិធីជ្រមុជទឹក មើលទៅដូចជាការមុជទឹក មិនមែនឲ្យមើលទៅដូចជាអ្នកណាម្នាក់ខ្លាចទទឹកខ្លួននោះទេ។ និយាយពីថូទឹកវិញ សូមរកថូណាដែលធំ បើធំដល់ថ្នាក់យើងអាចជ្រមុជមនុស្សម្នាក់បាន កាន់តែប្រសើរ។ ក្នុងទំហំប៉ុណ្ណេះ យើងអាចធ្វើពិធីជ្រមុទទឹកដោយការចាក់ទឹកលើ ហើយកូនក្មេងអាចឈរក្នុងថូនេះបាន។ តូចបំផុត ក៏ត្រឹមទំហំដែលក្មេងអាយុបីខែអាចមុជទឹកបាន។ វាគួរធំជាងចានដាក់ស្កររគ្រាប់[34] ដែលយើងតែងឃើញ។ ហេតុអីអញ្ចឹង? យើងមិនសូវប្រើចានដាក់ស្កររគ្រាប់ប៉ុន្មានទេ តែយើងមុជទឹកជាប្រចាំ។ ពេលយើងពិធីជ្រមុជទឹក មើលទៅដូចជាយើងមុជទឹក នោះការមុជទឹករបស់យើងរាល់ថ្ងៃ រំលឹកយើងពីព្រះគុណរបស់ព្រះ ដែលចាប់ផ្តើមក្នុងថ្ងៃដែលយើងទទួលពិធីជ្រមុជទឹក និងបន្តរហូតមក។

ពេលយើងចាក់បង្ហូរទឹកដែលក្រុមជំនុំអាចមើលឃើញ ហើយដោយគ្មានការលេងភ្លេងអមដើម្បីឲ្យមនុស្សអាចឮសំឡេងទឹក។[35] សូមកុំប្រញ៉ាប់។ ចំណាយពេលដើម្បីពិចារណា។ បើមានទឹកកំពុបលើកម្រាល (យើងបាននិយាយពីការនេះរួចហើយ) នេះជាការរំលឹកមួយថា យើងមិនអាចគ្រប់គ្រងព្រះវិញ្ញាណបានទេ។ ការឃើញ និងឮសំឡេងទឹក ធ្វើឲ្យយើងស្រម័យពីវិធីវិសុទ្ធដើម្បីបង្ហាញថា ទឹករំលឹកយើងពីការងារនៃព្រះគុណព្រះក្នុងពិភពលោក។

ក្នុង ទីថ្វាយបង្គំភឺគិនស៍ (Perkins) នៃសកលវិទ្យាល័យមេថូឌីស្ទខាងត្បូង ថូទឹកធ្វើពីស្ពាន់ ដែលបញ្ចេញសំឡេងដូចជាភ្លៀងពេលយើងចាក់ទឹកចូលវា។ សំឡេងនេះធ្វើឲ្យខ្ញុំនឹកចាំការមួយចំនួន។

ផ្ទះគ្រូគង្វាលទីមួយដែលប្រពន្ធខ្ញុំ និងខ្ញុំរស់នៅ មានប្រឡាយទឹកមួយ។ យើងដឹងពីវា ពេលឪពុកម្តាយខ្ញុំជួយខ្ញុំរើឥវ៉ាន់ចូលផ្ទះ។ ដោយសារខ្ញុំមិនដែលឃើញប្រឡាយទឹក ខ្ញុំសួរម្តាយខ្ញុំថា « តើវាមានន័យថាម៉េច?» ពេលនោះគឺខ្ញុះតែបីថ្ងៃទៀត ខ្ញុំអាយុ២២ឆ្នាំ ខ្ញុំគឺជាក្មេងដែលរស់នៅទីក្រុងតាំងពីតូច។ ខ្ញុំគិតថា ឲ្យតែបើក្បាលរូប៊ីណេ នោះនឹងមានទឹកចេញមក មិនបាច់មានប្រភព។ ពេលគាត់ឮសំនួររបស់ខ្ញុំ ម្តាយខ្ញុំឆ្លើយថា «កូនអើយ ប្រឡាយទឹកមានន័យថា បើអត់មានភ្លៀង កូនក៏អត់មានទឹកដែរ»

ថ្ងៃនោះខ្ញុំរៀនបានមេរៀនមួយដែលមនុស្សភាគច្រើនក្នុងពិភពលោកបានដឹងហើយ អំពីទំនាក់ទំនងរវាងទឹកភ្លៀង និងទឹកដែលយើងប្រើប្រាស់។ ខ្ញុំរៀនពីការនេះ ពេលខ្ញុំរស់នៅខាងជើងរដ្ឋតិចសាស ដែលមានមនុស្សទីក្រុងច្រើន ហើយគ្រោះរាំងស្ងួតអាចធ្វើឲ្យអាងស្តុក ទឹករីងស្ងួត ដ៏គួរឲ្យភ័យខ្លាច។ ដោយសារបទពិសោធន៍ទាំងនេះ ខ្ញុំចូលចិត្តស្តាប់សំឡេងទឹក ភ្លៀងលើដំបូលផ្ទះ ព្រោះវារំលឹកខ្ញុំពីព្រះគុណនៃការប្រទានរបស់ព្រះ និងព្រះគុណជុំវិញ ពិធីជ្រមុជទឹក។ ខ្ញុំមិនចូលចិត្តសោះពេលខ្ញុំឮអ្នកព្យាករអាកាសធាតុនិយាយថា «អាកាសធាតុ

---

[34] ដូចជាការចង្អុលបង្ហាញនេះ ខ្ញុំជំពាក់គុណចំពោះលោក L. Edward Phillips' discussion in *Baptism in The United Methodist Church, A Companion DVD to "By Water and the Spirit."* (Nashville, Tennessee: United Methodist Communications, 2007).

[35] *UMBOW*, paragraph 10, 90.

អាក្រក់ណាស់» ដោយសារភ្លៀង។ ទោះបីជាវាភ្លៀងឡើងជន់លេចក៏ដោយ ព្រោះទឹកជំនន់រំលឹកយើងពីការកាត់ទោសរបស់ព្រះ (លោកុប្បត្តិ ៦-៩, និក្ខមនំ ១៤-១៥) ដែលជាការពិតនៃធម្មជាតិ និងដូចជាព្រះវិញ្ញាណ ដែលមានអំណាចអស្ចារ្យ ដែលយើងមិនអាចគ្រប់គ្រងបាន។ អ្វីដែលល្អបំផុតដែលយើងគួរធ្វើជាមួយធម្មជាតិ គឺយើងគួរតាមដាន ហើយធ្វើតាម ទាំងការសន្សំទុក ការការពារទឹកជំនន់ និងគ្រប់ទាំងជីវិតទាំងអស់។

ការប្រើទឹកច្រើនក្នុងពិធីជ្រមុជ អាចជួយឲ្យយើងស្រម៉ៃ វាដូចជាសិល្បៈ ដែលយើងឃើញនៅលើថ្ម ឬរូងភ្នំ ឬជ្រលងភ្នំ។ វាបំពេញនូវសេចក្តីត្រូវការចេញពីសៀវភៅ អធិស្ឋាន «ព្រះអម្ចាស់អើយ សូមបើកភ្នែកមនុស្សទាំងអស់ ដើម្បីឲ្យគេឃើញស្នាព្រះហស្តរបស់ទ្រង់ ហើយឲ្យគេមានសេចក្តីអំណរជាមួយការទាំងអស់ដែលទ្រង់បង្កើត និងថ្វាយកិត្តិយសដល់ទ្រង់អស់ពីចិត្ត និងបំរើទ្រង់ដោយស្មោះស្ម័គ្រ។»[36]

---

[36] *The Book of Common Prayer* (New York: The Church Hymnal Corporation, 1979), 329.



# តើនេះជាពិធីជ្រមុជទឹករបស់អ្នកណា? តួនាទីផ្សេងៗក្នុងកម្មវិធី

យើងយល់ខុស ពេលយើងពិភាក្សាគ្នាអំពីវិធីវិសុទ្ធ ថាវាជាកិច្ចការរបស់គ្រូគង្វាលដែលមានប្រេងតាំង។ សូមកុំយល់ខុសអោយសោះ ក្នុងប្រពៃណីរបស់យើង គ្រូគង្វាលនាំមុខពិធីវិសុទ្ធ មិនមែនគ្រប់គ្រងពិធីនេះទេ។ នាំមុខ មានន័យថាមានអ្នកចូលរួមផ្សេងទៀត។ នាំមុខ មានន័យថាតួនាទីរបស់គ្រូគង្វាល គឺសំរាប់ជួយក្រុមជំនុំទាំងមូល ធ្វើវាឲ្យបានត្រឹមត្រូវ។ អ្នកនាំមុខជាគ្រូគង្វាលពិនិត្យមើលបេកជនដែលត្រូវទទួលពិធីជ្រមុជទឹក ដឹកនាំសេចក្ដីអធិស្ឋានសំរាប់ទឹក និងប្រើទឹកជាមួយរូបមន្តនៃពិធីជ្រមុជ។[37] ក្រុមជំនុំក៏ពិនិត្យ ហើយឆ្លើយតបដោយការគាំទ្រដល់បេកជន។ ក្រុមជំនុំចូលរួមជាមួយបេកជន និងអ្នកធានា ដោយការប្រកាសសេចក្ដីជំនឿគ្រីស្ទបរិសទ្ធ តាមសេចក្ដីជំនឿរបស់សាវ័ក។ ក្រុមជំនុំឆ្លើយតបជាមួយ សេចក្ដីអធិស្ឋានសំរាប់ទឹក ហើយនិយាយថា «អាម៉ែន» ពេលចុងបញ្ចប់។ ក្រុមជំនុំនិយាយថាអាម៉ែនម្ដងទៀត បន្ទាប់ពីគ្រូគង្វាលនិយាយពីរូបមន្តនៃពិធីជ្រមុជ។[38] ដូច្នេះក្រុមជំនុំទាំងមូល មានសកម្មភាពក្នុងកម្មវិធីជ្រមុជទឹក។

នៅមានទៀត។ កម្មវិធីសេចក្ដីសន្យានៃពិធីជ្រមុជ និយាយពីតួនាទីមួយចំនួនទៀត ក្រៅពីគ្រូគង្វាល។ យើងធ្លាប់និយាយពីការនេះម្ដងហើយ តែយើងនឹងនិយាយពីការនេះម្ដងទៀតដោយលំអិត។ ជាពិសេស

---

[37] *UMBOW*, paragraphs 4, 10-11, 88, 90-91.

[38] *UMBOW*, paragraph 11, 91.

- «អ្នកតំណាងក្រុមជំនុំនឹងណែនាំបេកជន...»[39] ការអនុវត្តន៍ដែលល្អបំផុត អ្នកណែនាំ គឺជាអ្នកស្គាល់បេកជន និងអ្នកធានា ហើយធ្លាប់ជួយគេក្នុងដំណើរនៃសេចក្តីជំនឿ។ នេះយើងឃើញដំណើរពីសេចក្តីសន្យានៃពិធីជ្រមុជទឹក ទៅកាន់កម្មវិធីជ្រមុជទឹក។
- អ្នកធានាបេកជន ទាំងសំរាប់អ្នកដែលមិនអាចនិយាយដោយខ្លួនឯង ជាពិសេសកុមារ និងសំរាប់អ្នកដែលអាចនិយាយ។[40] អ្នកធានាក៏ជាអ្នកដែលស្គាល់បេកជន និងអ្នកគាំទ្ររគេក្នុងដំណើរនៃសេចក្តីជំនឿ។
- ឌីកិន អាចនាំកម្មវិធីពេលដំបូង (¶1) ក្នុងការហៅឲ្យក្រុមជំនុំប្រកាសសេចក្តីជំនឿ (¶9) ហើយចាក់ទឹកចូលក្នុងថូសំរាប់ពិធីជ្រមុជទឹក (¶10)។
- តួនាទីផ្សេងទៀត មិនសូវមាននិយាយក្នុងកម្មវិធីទេ តែអាចមានលើកឡើង។ ឧទាហរណ៍
- ឌីកិនអាចធ្វើជា «អ្នកកាន់កម្មវិធី» ជុំវិញថូទឹក ជួយរៀបចំអ្នកផ្សេងទៀត និងការងារដែលចាំបាច់ ដើម្បីជួយដល់លោកគ្រូគង្វាលដែលដឹកនាំកម្មវិធី ឲ្យគាត់ផ្តោតលើការដឹកនាំសេចក្តីអធិស្ឋាន និងកម្មវិធីផ្សេងៗក្នុងពិធីជ្រមុជទឹក។
- អ្នកដឹកនាំចំរៀងអាចដឹកនាំការច្រៀងឆ្លើយឆ្លងជាមួយការអរព្រះគុណ សំរាប់ទឹក។[41] គាត់អាចដឹកនាំចំរៀងផ្សេងទៀតក្នុងកម្មវិធី ឬពេលដែលបេកជនដើរឆ្ពោះទៅកាន់ថូទឹក ឬពេលកម្មវិធីបញ្ចប់។ ឧទាហរណ៍ ដូចជាបទ "Take Me to the Water,"[42] "Water, River, Spirit, Grace,"[43] "Alleluia,"[44] "This is the Spirit's Entry Now,"[45] និង "You Have Put on Christ,"[46] ក៏មានបទផ្សេងមួយចំនួនទៀតដែរ។
- ឌីកិន អ្នកនាំភ្លេងទៀន ឬអ្នកជំនួយគ្រូគង្វាល អាចឈរនៅក្បែរថូ ជិតគ្រូគង្វាល កាន់សៀវភៅ ដើម្បីឲ្យគាត់មានដៃទំនេរសំរាប់ធ្វើកាយវិការ ពេលអរព្រះគុណសំរាប់ទឹក។

បើព្រះវិហារឲ្យអាវថ្មី ទាន ឬអំណោយផ្សេងទៀតសំរាប់រំលឹកពិធីជ្រមុជទឹក គួរមានអ្នកតំណាងក្រុមជំនុំសំរាប់ឲ្យអំណោយនេះដែរ។

---

[39] *UMBOW*, paragraph 3, 87.

[40] *UMBOW*, paragraphs 5 & 7, 88.

[41] "Baptismal Covenant Musical Responses," The United Methodist Hymnal (Nashville, Tennessee: The United Methodist Publishing House, 1989), 53-54.

[42] African American spiritual, *Worship and Song* (Nashville: Abingdon Press, 2011), 3165.

[43] Thomas H. Troeger (1987), *The Faith We Sing* (Nashville: Abingdon Press, 2000), 2253.

[44] Jerry Sinclair (1972), *UMH*, 186.

[45] Thomas E. Herbranson (1972), *UMH*, 608.

[46] ICEL (1969), *UMH*, 609.

ពេលក្រុមជំនុំយល់ពីតួនាទី និងទំលាប់ទាំងនេះ គេដើរតួរជាសង្ឃនៃអ្នករួមជំនឿទាំងអស់[47] ហើយពួកគេអាចមើលឃើញយ៉ាងច្បាស់ថា តើភាពជាសង្ឃនៃព្រះគ្រីស្ទ មានន័យយ៉ាងម៉េច ចំពោះការងារបំរើ ក្រៅពីការប្រជុំគ្នាថ្ងៃអាទិត្យ។ ប្រហែលគ្មានអ្វីដែលអាចបង្ហាញពីការនេះ ច្បាស់ជាងសេចក្តីអធិស្ឋានសំរាប់ព្រះវិញ្ញាណបរិសុទ្ធៈ

> បន្ទាប់ពីជ្រមុជទឹកឲ្យគេរួចហើយ គ្រូគង្វាលដាក់ដៃលើក្បាលបេកជន ហើយប្រកាសសូមព្រះវិញ្ញាណបរិសុទ្ធ។ អ្នកដទៃទៀត រួមទាំងគ្រួសារបេកជនផងដែរ អាចចូលរួមក្នុងសេចក្តីអធិស្ឋាននេះ...[48] (សង្កត់ន័យបន្ថែម)

គួរពិចារណាប្រើពិធីការនេះ។ ពេលមនុស្សអធិស្ឋាន គ្រូគង្វាលគួរឈប់ ហើយស្នើរសូមឲ្យក្រុមជំនុំ ចូលរួមជាមួយគាត់។ អ្នកដែលនៅជិតថ្លូទឹក អាចដាក់ដៃលើបេកជន អ្នកធានា ឬគ្រូគង្វាល។ អ្នកដទៃទៀតអាចដាក់ដៃលើអ្នកដែលនៅជិតចូ ហើយគេអាចលើកដៃ ឲ្យពរ។ ការអញ្ជើញអ្នកទាំងអស់គ្នា ចូលរួមក្នុងសេចក្តីអធិស្ឋាន ពេលនោះគ្រូគង្វាល មើលទៅអ្នកដែលទើបទទួលពិធីជ្រមុជទឹក ហើយនិយាយថាៈ

> ព្រះវិញ្ញាណបរិសុទ្ធ ធ្វើការជាមួយអ្នក
> ការដែលអ្នកចាប់កំណើតជាថ្មីដោយទឹក និងព្រះវិញ្ញាណ
> សូមឲ្យអ្នកជាសិស្សរបស់ព្រះគ្រីស្ទដោយស្មោះត្រង់[49]

ដូចដែលខ្ញុំបានសរសេរខាងលើ អ្នកទាំងអស់គ្នានឹងនិយាយរួមគ្នាថា «អាម៉ែន»។ ការដែលក្រុមជំនុំចូលរួមទាំងអស់គ្នាដូចនេះ មានន័យថាយើងទាំងអស់គ្នាមានការទទួលខុសត្រូវសំរាប់គ្នាទៅវិញទៅមក ក្នុងព្រះគ្រីស្ទ។ បើយើងធ្វើពិធីនេះញយដង អត្ថន័យរបស់វា និងជ្រាបចូលដល់ឆ្អឹងរបស់យើង។

---

[47] See I Corinthians 12, especially vv. 12-13 and I Peter 2:1-10, especially vv. 9-10.

[48] *UMBOW*, paragraph 11, 91.

[49] *UMBOW*, paragraph 11, 91.



# តើអ្វីនឹងកើតមានបន្ទាប់? តម្រុយពីប្រវត្តិសាស្ត្រ និង ពិធីការ

អត្ថន័យ ភាគច្រើនលេចមកក្នុងបរិបទ ក៏ដូចជាពិធីជ្រមុជទឹកដែរ ដែលអ្វីដែលកើតឡើងបន្ទាប់ អាចជួយឲ្យយើងយល់ពីអត្ថន័យ និងកន្លែងដែលវានឹងនាំយើងទៅ។ ការដាក់ដៃលើ ដោយ សេចក្តីអធិស្ឋាន ដែលយើងបាននិយាយខាងលើ គឺជាកាយវិការដែលមានឫសក្នុងព្រះ គម្ពីរ ដែលគេប្រើតាំងពីយូរណាស់មកហើយ ដើម្បីចាត់អ្នកណាម្នាក់ឲ្យចេញទៅបំពេញបេសកកម្ម ក្នុងជីវិត (ជនគណនា ២៧៖១៨ ចោទិយកថា ៣៤៖៩ កិច្ចការ ៩៖១៧ និង ១ធីម៉ូថេ ៤៖១៤)[50] យើងធ្លាប់ឃើញការនេះនៅពិធីចាក់ប្រេងតាំង វាក៏មានប្រវត្តិយ៉ាងជ្រៅក្នុងកម្មវិធី ជ្រមុជទឹក និង បញ្ជាក់ពីសេចក្តីជំនឿ។ ពិតណាស់ ក្នុងទំលាប់របស់យូណៃធីតមេថូឌីស្ទ ពិធីបញ្ជាក់ពីសេចក្តី ជំនឿ គឺជាពិធីបន្ថែមលើសេចក្តីសន្យានៃពិធីជ្រមុជទឹក។[51] យើងក៏អាចធ្វើការដាក់ដៃលើ នៅក្នុង ពិធីមង្គលការផងដែរ[52] និងក្នុងពិធីនៃការតាំងចិត្តក្នុងការងារ អ្វីមួយក្នុងជំនឿគ្រីស្ទបរិសទ្ធ។[53] ពេលដែលវាកើតឡើង ការអធិស្ឋានដាក់ដៃលើ ចង្អុលប្រាប់យើងឲ្យឆ្ពោះទៅកាន់បេសកកម្ម របស់យើង «ការដែលយើងបានកើតជាថ្មីដោយទឹក និងដោយព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកអាច រស់នៅជាសិស្សដ៏ស្មោះស្ម័គ្ររបស់ព្រះគ្រីស្ទ។[54] ការងារគ្រីស្ទបរិសទ្ធ មានទម្រង់ផ្សេងគ្នា

---

[50] "Laying on of Hands," *The New Interpreter's Dictionary of the Bible, Volume 3* (Nashville: Abingdon Press, 2008), 615.

[51] *UMBOW*, paragraph 12, 92.

[52] "The Service of Christian Marriage I," *UMBOW*, 122.

[53] "An Order for Commitment to Christian Service," *UMBOW*, 591.

[54] *UMBOW*, paragraph 12c., 92.

ជាច្រើន តែការមួយដូចគ្នា សំរាប់គ្រប់អស់អ្នក ដែលបានទទួលពិធីជ្រមុជទឹក នោះគឺការអធិស្ឋានសំរាប់ពិភពលោក។ ដូចដែលយើងបានឃើញក្នុងព្រះគម្ពីរកិច្ចការ និងសៀវភៅគ្រីស្ទបរិសទ្ធពីបុរាណ ដូចជាក្នុងសត្តវត្សទី២ ដែលមានចំណងជើងថា First Apology of Justin Martyr, ការដំបូងដែលគេធ្វើបន្ទាប់ពីទទួលពិធីជ្រមុជទឹក គឺគេចូលរួមអធិស្ឋានក្នុងសហគមន៍។[55] «អ្វីជាការបន្ទាប់?» គឺជាការត្រាស់ហៅឲ្យអធិស្ឋានសំរាប់ពិភពលោក ហើយការសំខាន់ដូចគ្នានេះគឺការអធិស្ឋានដោយកាយវិការ ដែលជាការធ្វើការដោយដៃ និងជើង។[56]

តម្រុយទីពីរអំពី «អ្វីជាការបន្ទាប់?» មានចែងក្នុងពិធីការនៃសេចក្តីសន្យាជ្រមុជទឹក។ វាចែងថា

> កម្មវិធីសេចក្តីសន្យានៃពិធីជ្រមុជទឹក គឺល្អបំផុតបើមានពិធីលៀងព្រះអម្ចាស់ ដែលការចូលរួមរបស់សមាជិកថ្មី ជាមួយរូបកាយរបស់ព្រះគ្រីស្ទ ត្រូវបានបើកសម្តែង យ៉ាងច្បាស់។ សមាជិកថ្មី រួមទាំងកុមារផងដែរ អាចនាំនំប៉័ង និងទឹកទំពាំងបាយជូ មកកាន់តុរបស់ព្រះអម្ចាស់ ហើយពួកគេជាអ្នកទទួលចំណិតនំប៉័ង និងទឹកទំពាំងបាយជូមុនគេ ហើយគេអាចជួយបម្រើពិធីនេះ។[57]

ពិធីលៀងព្រះអម្ចាស់ ទាក់ទងនិងពិធីជ្រមុជទឹក ហើយពិតណាស់ថាវាជាពិធីក្នុងជំនឿគ្រីស្ទបរិសទ្ធ ដែលកើតឡើងម្តងហើយម្តងទៀត។ ពិធីការមិនមែនគ្រាន់តែឲ្យដឹងថា «អ្នកណាត្រូវធ្វើអីនោះទេ» ព្រោះវាអាចធ្វើឲ្យមនុស្សគិតថាខុស ថាតើអ្នកណាមានអំណាចប៉ុណ្ណា។ វាល្អបំផុត បើយើងអានពិធីការនេះ ដោយគិតពីបេសកកម្ម។ ដូចជាអ្នកដែលមានទំនាក់ទំនង ជាមួយព្រះយេស៊ូវគ្រីស្ទ យើងធ្វើការអរព្រះគុណ ហើយជាងនេះទៅទៀត គឺយើងរស់នៅក្នុងជីវិតលះបង់ និងការបំរើ។ យើងទទួលបានរូបកាយ និងលោហិតរបស់ព្រះគ្រីស្ទ «ដែលយើង រស់នៅជារូបការព្រះគ្រីស្ទសំរាប់ពិភពលោក  ហើយយើងបានសេចក្តីប្រោសលោះ ដោយសារព្រះលោហិតទ្រង់។»[58]

ម្តងទៀត ពិធីជ្រមុជទឹក សង្គ្រោះយើង ប៉ុន្តែមិនមែនជាការសង្គ្រោះបុគ្គល ដូចជាការបង្រៀនរបស់អ្នកខ្លះនោះទេ។ តាមរយៈសេចក្តីសន្យានៃពិធីជ្រមុជទឹក និងសហគមន៍នៃសេចក្តីជំនឿ

---

[55] *The First Apology of Justin Martyr, in The Ante-Nicene Fathers, Translations of the Writings of the Fathers down to A.D. 325,* ed. Alexander Roberts and James Donaldson, vol. 1 (Grand Rapids: Eerdmans, n.d.) chapter 65, p. 185.

[56] សំរាប់ការពិភាក្សាវែងអំពីការទាំងនេះ សូមមើល Mark W. Stamm, *Devoting Ourselves to the Prayers, A Baptismal Theology for the Church's Intercessory Work* (Nashville, Tennessee: Discipleship Ministries, 2014).

[57] "The Baptismal Covenant I," paragraph 16. https://www.umcdiscipleship.org/resources/the-baptismal-covenant-i

[58] *UMBOW*, 38.

ព្រះបានដកចេញការអំពុលពីយើង ដោយបំពេញសេចក្ដីត្រូវការ និងជោគវាសនារបស់យើង ហើយប្រទានឲ្យយើងនូវការងារមួយសំរាប់ជាព្រះពរដល់ពិភពលោក និងហៅយើងឲ្យមានសេចក្ដីយុត្តិធម៌ និងសេចក្ដីស្រឡាញ់។ ភាគច្រើន យើងស្គាល់ពីគោលបំណង និងគោលដៅសំរាប់ជីវិត ពេលយើងមានបេសកកម្មជាមួយអ្នកដទៃ។



# សំនួរញឹកញាប់ អំពីការអនុវត្តន៍ពិធីជ្រមុជទឹក របស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ

**សៈ** សៀវភៅវិន័យរបស់យូណៃធីតមេថូឌីស្ទ បង្គាប់ឲ្យយើងបង្រៀនបេកជន សំរាប់ពិធីជ្រមុជទឹក និងអ្នកធានា។[59] តើយើងយល់យ៉ាងណាចំពោះតម្រូវការនេះ?

**ចៈ** វាជាការល្អ ពេលដែលបេកជន អ្នកធានា និងគ្រូគង្វាល ដឹងពេលណាត្រូវធ្វើអី កន្លែងត្រូវឈរ និងអ្វីត្រូវនិយាយ។ ដូចជាមង្គលការ ការសមជារឿងសំខាន់បំផុត។ ប៉ុន្តែ សូមចំណាំថា ក្នុងបរិបទគ្រីស្ទបរិសទ្ធពីបុរាណ ពិធីជ្រមុជទឹកដំបូង បេកជនគ្មានសាក្សី ក្រៅពីរូបគេនោះទេ។ ខ្ញុំមិនមែនចង់ឲ្យយើងធ្វើបែបនេះទេ តែវាជួយឲ្យយើងយល់ពីពាក្យថា «បង្គាប់»។ ការបង្រៀនរបស់ក្រុមជំនុំសម័យដើម បេកជនរៀបចំសម្រាប់ពិធីជ្រមុជទឹក ដោយការជ្រមុជក្នុងព្រះគម្ពីរ ហើយអ្នកធានានឹងបន្តធ្វើជាអ្នកណែនាំពួកគេ ក្នុងការធ្វើជាសិស្សរបស់ព្រះគ្រីស្ទ ជួយឲ្យគេទទួលព្រះបន្ទូលរបស់ព្រះ ហើយរស់នៅដោយការឆ្លើយតបចំពោះការត្រាស់ហៅ។

ខ្ញុំក៏មិនបានឲ្យយើងធ្វើតាមការបង្រៀនរបស់ក្រុមជំនុំសម័យដើមដែរ ព្រោះការបង្រៀននេះអាចចំណាយពេលបីឆ្នាំ ឬយូរជាង។[60] ប៉ុន្តែ វាល្អជាងបើយើង គិតពីការបង្រៀនរបស់លោកវេស្លី ដែលវាជាការយន្តការនៃការបង្កើតជីវិតខាងព្រលឹងវិញ្ញាណ ដែលមិនមែនជាការពិភាក្សា ឬការបង្រៀននោះទេ។ ក្នុងគំរូនេះ ការបង្រៀនមុនពេលជ្រមុជទឹក វាដូចជាការប្រជុំគ្នារបស់មេថូឌីស្ទ ដែលមិនមែនជាថ្នាក់រៀនដូចជាអ្វីដែលយើងដឹងនោះទេ តែវាជារបៀបមេជាង បង្រៀនកូនជាងក្នុងលក្ខណៈជាសិស្សរបស់ព្រះគ្រីស្ទ។ បើប្រៀបទៅពិធី

[59] *Discipline*, 2016, paragraphs 216.1.a-b, and 226.1.

[60] Bradshaw, Johnson, and Phillips, *The Apostolic Tradition*, 17:1-2, p. 96.

មង្គលការវិញ សូមយើងគិតពីភាពខុសគ្នារវាងការសមមុនពេលការ និងការប្រឹក្សាយោបល់មុនពេលរៀបការ។ គោលដៅសំខាន់បំផុតក្នុងការប្រឹក្សាយោបល់មុនពេលរៀបការ គឺដើម្បីឲ្យគេរស់នៅជាគ្រីស្ទបរិសទ្ធ។ ការប្រឹក្សាយោបល់ ដែលល្អ គឺធ្វើជាមួយប្តីប្រពន្ធ បីបួនគូរផ្សេងទៀត ដោយឲ្យអ្នកដែលមានបទពិសោធន៍ ច្រើនធ្វើជាអ្នកជួយណែនាំ។

សាកស្រម័យមើលថា បើការរៀនពីខ្លឹមសារពិធីជ្រមុជទឹក ត្រូវបានរៀបចំដូចគ្នានេះ ដោយប្រើរដូវឡិន (Lent) ដើម្បីរៀន ហើយពិធីជ្រមុជទឹក នៅថ្ងៃព្រះគ្រីស្ទរស់ឡើងវិញ។ បើក្រុមជំនុំ ធំល្មម អាចធ្វើជាបីបួនក្រុម មួយសំរាប់អ្នកធានា មួយសំរាប់បេកជន។ គេអាចអានព្រះគម្ពីរ សំរាប់ឆ្លើយសំនួរនៃពិធីជ្រមុជ ឧទាហរណ៍ «តើបទគម្ពីរនេះ និយាយពីការអាក្រក់យ៉ាងដូចម្តេច ហើយតើព្រះគម្ពីរចង់ឲ្យយើងធ្វើអ្វី ដើម្បីប្រឆាំងការអាក្រក់នេះ?»[61] គំរូនៃការបង្រៀននេះ មានក្នុងយូណៃធីតមេថូឌីស្ទ និងនិកាយផ្សេងៗដែរ។[62] គ្រូគង្វាល និងឌីកិន ត្រូវត្រួតពិនិត្យការងារនេះ តែបើការនេះធ្វើជាមួយក្រុមសិស្សនៃសេចក្តីសន្យា នោះការដឹកនាំចម្បង នឹងត្រូវកើតពីសមាជិកក្រុមជំនុំ។

**សៈ** បើនណាម្នាក់ឆ្លើយតបចំពោះការអញ្ជើញជាសាធារណៈឲ្យក្លាយជាសិស្សរបស់ព្រះគ្រីស្ទ តើយើងគួរធ្វើពិធីជ្រមុជគាត់នៅពេលនោះមែនទេ?

**ចៈ** ពីធីជ្រមុជទឹកបែបនេះវាដូចជាចំឡែកពេកហើយ ខ្ញុំគិតថាវាមិនមែនជាការអនុវត្តន៍ល្អនោះទេ ហើយខ្ញុំមានហេតុផលពីរយ៉ាង។ ទីមួយ ដូចដែលយើងបាននិយាយពីមុន វាដូចជាច្បាស់ហើយ។ ទោះជាយើងយល់ពីតម្រូវការនៃការបង្រៀនបេកជន ពាក្យខ្សិបគ្នាពីរបីម៉ាត់រវាងគ្រូគង្វាល និងបេកជន ពិតជាមិនគ្រប់គ្រាន់ទេ។ យើងដឹងហើយថា មានគ្រីស្ទបរិសទ្ធតែសំបកក្រៅជាច្រើន ក្នុងសង្គមអាមេរិកាំង ព្រោះយើងតែងភ្លេចថា ការទទួលពិធីជ្រមុជទឹក តម្រូវឲ្យមានការតាំងចិត្តខ្ពស់។ ការជ្រមុជទឹកក្នុងសេចក្តីស្លាប់របស់ព្រះគ្រីស្ទ (រ៉ូម ៦៖៣-៤) ទាមឬទារឲ្យយើងស្លាប់ចំពោះខ្លួនឯង ឬយ៉ាងហោចណាស់ ទទួលអ្នកណាម្នាក់ដែលចំឡែក ហើយពិបាក ឲ្យចូលក្នុងក្រុមជំនុំ។ ពេលយើងណែនាំកុម៉ារឲ្យទទួលពិធីជ្រមុជទឹក យើងស្ម័គ្រចិត្តឲ្យគេទទួលជីវិតបែបនេះដែរ។ ពាក្យចាស់បុរាណនិយាយថា « ដូច្នេះកុំឲ្យយើងចូលមកដោយគ្មានការពិចារណា»[63] ។ យ៉ាងហោចណាស់ ក៏គួរមានការពិភាក្សាគ្នាជាលក្ខណៈឯកជន មុនពេលធ្វើពិធីនេះដែរ។
មានការដែលគួរឲ្យបារម្ភណ៍មួយទៀត អំពីការជ្រមុជទឹកលឿនពេក។ ក្នុងករណីដែលមាន

---

[61] Compare *UMBOW*, paragraph 4, p. 88.

[62] See "For Further Reading, " Benedict, Bushofsky *et al.*, and Edie.

[63] "A Service of Christian Marriage II, *UMBOW*, 129. ភាសាដែលគួរឬមិនគួរប្រើ មានក្នុងសៀវភៅអធិស្ឋាន របស់យូណៃធីតមេថូឌីស្ទ ដែលសរសេរតាំងពីឆ្នាំ១៥៤៩។ http://justus.anglican.org/resources/bcp/1549/Marriage_1549.htm Accessed June 23, 2016.

មនុស្សម្នាក់ថ្វាយខ្លួនភ្លាមៗ យើងមិនដឹងថាគេធ្លាប់ទទួលពិធីជ្រមុជពីមុនមក ឬនៅហើយ ការដែលគ្មានពេលនិយាយគ្នា នោះជាបញ្ហា។ បើអ្នកនោះទទួលពិធីជ្រមុជរួចហើយ នោះយើងមិនបាច់ចំណាយពេលពិភាក្សាពិធីការទេ។

ដូច្នេះតើយើងត្រូវធ្វើដូចម្តេច ពេលមានអ្នកណាម្នាក់ថ្វាយខ្លួន? យើងគួរស្វាគមន៍គេ ដោយសេចក្តីអំណរ និងការអធិស្ឋាន។ យើងគួររៀបចំដៃគូបង្រៀនម្នាក់ ដែលនិងបន្ត ការសន្ទនាជាមួយគេ ហើយអាចជួយឲ្យគេធ្វើពិធីជ្រមុជទឹកនាពេលឆាប់ៗខាងមុខ។

**ស៖** តើការបញ្ជាក់សេចក្តីជំនឿ និងពិធីជ្រមុជទឹក ទាក់ទងគ្នាយ៉ាងណាដែរ? តើវាចាំបាច់ទេ?

**ច៖** ពាក្យថា «បញ្ជាក់សេចក្តីជំនឿ» គឺជាពាក្យពិធីការដែលគេបញ្ចូលក្នុងនិកាយមេថូឌីស្ទ ក្នុងប្រទេសអាមេរិក ដែលមានចែងក្នុងសៀវភៅថ្វាយបង្គំ សំរាប់ក្រុមជំនុំ និងតាមផ្ទះ (១៩៦៤)។[64] ទោះបីវាថ្មីសំរាប់យូណៃធីតមេថូឌីស្ទ ពេលមានការប្រជុំស្តីពី ការជ្រមុជទឹក ដោយទឹក និងព្រះវិញ្ញាណ ក្នុងឆ្នាំ ១៩៨៨-១៩៩២ ពាក្យនេះត្រូវបានគេស្នើសុំឲ្យកាត់ចេញ តែការស្នើសុំនេះត្រូវបានគេបដិសេធន៍។ ដូច្នេះ ការបញ្ជាក់សេចក្តីជំនឿ នៅតែជាការអនុវត្តន៍ដែលស្មើនិង «ការប្រកាសជាសាធារណៈដំបូង ដែលមនុស្សម្នាក់ទទួលព្រះគុណ ក្នុងពិធីជ្រមុជទឹក និងការទទួលស្គាល់ព្រះគុណដោយសេចក្តីជំនឿ។»[65] ការបញ្ជាក់សេចក្តីជំនឿ ក្លាយជាវិធីមួយដែលមនុស្សម្នាក់ក្លាយជាសមាជិកក្រុមជំនុំយូណៃធីតមេថូឌីស្ទ។

សូមចំណាំថា ការបញ្ជាក់សេចក្តីជំនឿ ធ្វើស្រដៀងនិងពិធីជ្រមុជទឹកដែរ ការអធិស្ឋានដាក់ដៃលើ ហើយធ្វើការជ្រមុជទឹកភ្លាម (សូមមើលការពិភាក្សាខាងលើ)។ ការបញ្ជាក់សេចក្តីជំនឿ យើងប្រើសេចក្តីអធិស្ឋានដូចគ្នា

> ព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងអ្នក
> ការដែលអ្នកបានកើតជាថ្មីតាមរយៈទឹក និងព្រះវិញ្ញាណបរិសុទ្ធ
> សូមឲ្យអ្នករស់នៅជាសិស្សស្មោះត្រង់របស់ព្រះគ្រីស្ទ។[66]

យើងអាចប្រើទឹក «ជានិមិត្តរូប តែមិនមែនជាការជ្រមុជទឹក» ដូចជាគ្រូគង្វាលនិយាយថា «

---

[64] "The Order for Confirmation and Reception into the Church," *The Book of Worship for Church and Home* (Nashville: The Methodist Publishing House, 1964), 12-14.

[65] "By Water and the Spirit: A United Methodist Understanding of Baptism," *The Book of Resolutions of The United Methodist Church 2016* (Nashville: The United Methodist Publishing House, 2016), 721.

[66] *UMBOW*, paragraph 12, 92.

សូមចាំពិធីជ្រមុជរបស់អ្នក ហើយអរព្រះគុណ»[67] ដូច្នេះ ការបញ្ជាក់សេចក្តីជំនឿ ទាក់ទងនិង ពិធីជ្រមុជ ជាការពង្រឹងគ្រឹះនៃអំណោយទាននៃពិធីជ្រមុជទឹក។[68] យោងតាមគោលការណ៍ របស់យើង ការបញ្ជាក់សេចក្តីជំនឿមានសារៈសំខាន់ ហើយវាមានប្រយោជន៍ សំរាប់ធ្វើការ ប្រកាសសមាជិកភាព។

**សៈ** តើពាក្យថា «សូមចាំពិធីជ្រមុជរបស់អ្នក ហើយអរព្រះគុណ» មានន័យដូចម្តេច?

**ចៈ** ដូចជាការដែលយើងអរព្រះគុណសំរាប់ពិធីវិសុទ្ធ យើងត្រូវតែគិតឲ្យជ្រៅជាង ការចងចាំ បុគ្គល។ ឧទាហរណ៍ ខ្ញុំចាំបានកាលខែ៤ ឆ្នាំ១៩៨៥ ដែលព្រិលធ្វើអោយការប្រកួតរបស់ ក្រុម បាលទីម៉រ និងក្រុមតិចសាស់ ត្រូវពន្យាពេល។ ពេលរសៀលនោះ កីឡាករ Eddie Murray បានយកឈ្នះដោយវាយបាល់នូវនាទីចុងក្រោយ។ ខ្ញុំអង្គុយជាមួយ ឪពុកខ្ញុំ និងមិត្ត ភក្រ័ខ្ញុំពីរនាក់ដែលជាគ្រូគង្វាលដែរ និងម្នាក់ទៀតដែលបានរៀបការ និងជ្រមុជទឹកឲ្យខ្ញុំ ពេលខ្ញុំនៅក្មេង។ យើងពាក់អាវរងារ ហើយខ្ញុំត្រជាក់ចង់រឹងអស់ហើយ។ ខ្ញុំចងចាំ ថ្ងៃនោះ ហើយខ្ញុំអាចនិយាយវាឡើងវិញបាន។ ប៉ុន្តែពេលក្រុមជំនុំនិយាយថា «សូមចាំពិធីជ្រមុជ របស់អ្នក ហើយអរព្រះគុណ» យើងមិនមែនចង់និយាយពីការចងចាំបែបនេះទេ។ សំរាប់ អស់អ្នកដែលបានទទួលពិធីជ្រមុជទឹកពេលនៅក្មេង យើងពិតជាមិនអាច ចងចាំការ ជ្រមុជទឹករបស់យើងបានទេ។

«សូមចាំពិធីជ្រមុជរបស់អ្នក» គឺជាភាសា មិនមែនជាការនឹករឿងដើម តែវាជាការចងចាំ ដែលក្នុងភាសាក្រិក យើងបកប្រែថា «ធ្វើការនេះទុកជាសេចក្តីរំលឹកដល់ខ្ញុំ»[69] ឃ្លានេះ ដែល មានក្នុងដំណឹងល្អ ហើយនិងការអរព្រះគុណ ប្រាប់យើងមិនឲ្យចាំរូបភាពនៃពិធីលៀង ព្រះអម្ចាស់ ដូចជាយើងបាននៅទីនោះដែរ តែគឺឲ្យយើងចាំពីអ្វីដែលព្រះគ្រីស្ទ បានធ្វើសំរាប់ យើង។ យើងចាំកន្លែងនេះ ព្រោះយើងបានឮពីព្រះគម្ពីរ។ ក្នុងពិធីលៀងព្រះអម្ចាស់ ការចូលរួមរបស់យើង ដោយសេចក្តីអធិស្ឋាន និងការទទួលចំណិតនំប៉័ង និងទឹកទំពាំង បាយជូរ ធ្វើឲ្យចងចាំនោះមានសុពលភាព។ ការធ្វើយ៉ាងនេះ យើងចងចាំកិច្ចការ សង្គ្រោះ របស់ព្រះ ក្នុងប្រវត្តិនៃគ្រួសារធំ ដែលយើងបានចូលរួម ដោយទឹក និងព្រះវិញ្ញាណ។ ពិត ណាស់ អំណោយទានរបស់ព្រះក្នុងពិធីជ្រមុជ[70] ត្រូវបានប្រគល់ឲ្យដល់ពិភពលោក ទៅ ក្រុមជំនុំ ហើយចុងក្រោយ គឺឲ្យមកយើងម្នាក់ៗ តាមក្រុមជំនុំ។

---

[67] Ibid.

[68] Resolutions 2016, 721.

[69] លូកា ២២៖១៩ និង ១កូរិនថូស១១៖២៤-២៥។ See also *UMBOW*, 37-38.

[70] អេភេសូ៤៖៥ និងឃ្លាក្នុង Nicene Creed, "យើងទទួលស្គាល់ពិធីជ្រមុជទឹកមួយ សំរាប់ការអត់ទោសបាប" *UMH*, 880.

**សៈ** ពិធីការនៃការបញ្ជាក់ឡើងវិញ សំរាប់សេចក្តីសន្យាពិធីជ្រមុជទឹកចែងថា «ទឹកអាចប្រើបាន តែមិនអាចបកប្រែជាពិធីជ្រមុជទឹកទេ»[71] តើយើងធ្វើតាមពិធីការនេះយ៉ាងម៉េច? តើអ្វីដែលអាចធ្វើបាន អ្វីដែលមិនអាចធ្វើបាន?

**ចៈ** ពិធីការនេះត្រូវបានសរសេរឡើងដើម្បីកុំឲ្យមានការធ្វើពិធីជ្រមុជទឹកឡើងវិញ។ ហេតុអីបានចាំបាច់ធ្វើដូចនេះ? យើងគួរចងចាំថា ពិធីវិសុទ្ធ គឺជាសញ្ញានៃការគាំទ្រ និងបកប្រែដោយពាក្យសម្តី។ ពាក្យ និងសកម្មភាព សំខាន់ទាំងពីរ តែសកម្មភាពសំខាន់ជាង។ ដូច្នេះ វាមិនមែនជាការស្មោះត្រង់ ហើយច្រឡំ បើយើងនាំអ្នកណាម្នាក់ទៅអាងហែលទឹក ជ្រមុជទឹកដល់គេ ហើយនិយាយថា «វាគ្រាន់តែជាការបញ្ជាក់ឡើងវិញ ព្រោះខ្ញុំបាននិយាយថា សូមចាំពិធីជ្រមុជរបស់អ្នក ហើយអរព្រះគុណ» ពិធីការនេះ ប្រឆាំងនិងការ អនុវត្តន៍ ឬអាចនិយាយថា «កុំធ្វើពិធីជ្រមុជទឹក ហើយហៅថាជាអ្វីផ្សេង។»

ដូច្នេះត្រូវធ្វើយ៉ាងម៉េច? ខ្ញុំជឿថា ការដែលយើងធ្វើតាមពិធីការ គឺជាការសំខាន់ ក្នុងនាម ជាគ្រូគង្វាល អនុវត្តដោយការតាំងចិត្ត ហើយបន្តរៀនពីអត្ថន័យនៃពិធីជ្រមុជទឹក។ ដូច្នេះ ពេលអ្នក និងក្រុមថ្វាយបង្គំរបស់អ្នក ធ្វើការវាយតំលៃ បន្ទាប់ពីពិធីបញ្ជាក់នៃពិធីជ្រមុជទឹក សូមសួរខ្លួនឯងថា អ្នកបានធ្វើតាមពិធីការ ឬអ្នកបានធ្វើពិធីជ្រមុជទឹកឡើងវិញ ឬអ្វីមួយដែលស្រដៀង ដោយប្រើឈ្មោះផ្សេង។ បើអ្នកធ្វើអ្វីដែលស្រដៀង សូមឈប់ភ្លាម។ វគ្គក្រោយខ្ញុំនឹងនិយាយពីមូលហេតុដែលយើងមិនធ្វើពិធីជ្រមុជឡើងវិញ។

ពេលខ្ញុំធ្វើពិធីបញ្ជាក់នៃពិធីជ្រមុជទឹកឲ្យអ្នកណាម្នាក់ ខ្ញុំបានសំរេចចិត្តថា ខ្ញុំនឹងមិនប្រើទឹកទេ ព្រោះវាស្រដៀងនិងពិធីជ្រមុជទឹកពេក។ ដូច្នេះខ្ញុំធ្វើការមួយចំនួន។ ការងារនៅ សាលាភីគិនស៍ ខ្ញុំលេងជាមួយទឹកបន្តិច រួចហើយខ្ញុំប្រោសទឹកដាក់អ្នកនោះ ដោយមិនគិតថាត្រូវ ឬមិនត្រូវនោះទេ។ ហើយខ្ញុំអញ្ជើញឲ្យក្រុមជំនុំដើរមករកទឹក ហើយអាចធ្វើអ្វីដែលគេគិតថាល្អ។ ខ្ញុំស្នើរឲ្យគេប៉ះទឹកនោះ ហើយធ្វើសញ្ញាឈើឆ្កាងលើថ្ងាស់គេ។ គោលបំណងសំខាន់គឺគេធ្វើអ្វីដែលគេចង់ធ្វើ ហើយបន្ទាប់ពីអរព្រះគុណសំរាប់ទឹក ខ្ញុំមិនមែនជាចំនុចកណ្តាលនៃពិធីការនោះទេ។ ពួកគេវិញ ដែលនៅកណ្តាល។

**សៈ** ហេតុអ្វីការធ្វើពិធីជ្រមុជឡើងវិញ ជាបញ្ហាដែលអាចប្តឹងបាន?[72] ហេតុអ្វីយើងមិនអាចធ្វើបាន?

**ចៈ** ក្រុមជំនុំយើងទទួលថា ពិធីជ្រមុជទឹក «នាំយើងចូលក្នុងក្រុមជំនុំព្រះគ្រីស្ទ និងការសង្គ្រោះដ៏អស្ចារ្យរបស់ព្រះ។»[73] តាមរយៈការនេះ ព្រះបានតាំងសេចក្តីសញ្ញាជាមួយយើង

---

[71] *UMBOW*, paragraph 12, 92.

ទទួលយើងជារាស្ត្ររបស់ទ្រង់ ដែលជាសកម្មភាពរបស់ព្រះដែលមិនអាចប្រកែកបាន។ «ដោយទឹកនិងព្រះវិញ្ញាណ» មានន័យថា៖

> ការប្រកាសថា ពិធីជ្រមុជទឹកមិនអាចធ្វើឡើងវិញបាន គឺស្ថិតនៅលើសេចក្តីស្មោះត្រង់ របស់ព្រះ។ ការចាប់ផ្តើមរបស់ព្រះ បង្កើតជាសេចក្តីសញ្ញានៃព្រះគុណដែលយើងទទួលបានក្នុងពិធីជ្រមុជទឹក... យើងប្រហែលជារស់នៅដោយមិនខ្វាយខ្វល់ចំពោះ សេចក្តីសញ្ញានេះ តែយើងមិនអាចបំផ្លាញសេចក្តីស្រឡាញ់របស់ព្រះដល់យើងបានទេ។[74]

ក្រុមជំនុំតែងទទូចតាំងពីយូរមកហើយថា ការសារភាពបាបគឺចាំបាច់សំរាប់អ្នកដែលព្រងើយចំពោះសេចក្តីសញ្ញាជាមួយព្រះ តែមិនមែនការធ្វើពិធីជ្រមុជទឹកជាថ្មីនោះទេ។[75] សេចក្តីសន្យារបស់ព្រះនៅដដែល។ អ្វីដែលយើងជាគ្រីស្ទបរិសទ្ធត្រូវធ្វើ ដូចជាការអានព្រះគម្ពីរ ការអធិប្បាយ ការអធិស្ឋាន សេចក្តីសង្ឃឹមសំរាប់ពិភពលោកដែលមានយុត្តិធម៌ និងគ្រប់ជីវិតដ៏វិសុទ្ធ។ ការទាំងនេះស្ថិតនៅលើសេចក្តីជំនឿចំពោះព្រះ ដែលការដែលទ្រង់ បានសង្គ្រោះមនុស្សលោក នៅតែដដែល។ ពេលដែលគ្រីស្ទបរិសទ្ធធ្វើពិធីជ្រមុជម្តងទៀត យើងមើលស្រាលដល់សេចក្តីជំនឿចំពោះព្រះ។

តាំងពីដើមមក គ្មានអ្នកណាអនុញ្ញាតិឲ្យមានពិធីជ្រមុជទឹកឡើងវិញនោះទេ ទោះបីប្រហែលមានអ្នកខ្លះប្រកែក។ ឧទាហរណ៍ ក្នុងសត្តវត្សទី១៦ និកាយអាណាបាបទីស្ទ (ដែលមានន័យថា ជ្រមុជទឹកឡើងវិញ) បានបដិសេធន៍ការជ្រមុជទឹកដល់កុមារ ដែលខុសពីនិកាយកាតូលិក និងនិកាយកែទម្រង់ (Reformers) មួយចំនួនដូចជានិកាយក្រុមជំនុំប្រទេសអង់គ្លេស។ វាមិនយុត្តិធម៌ទេ ដែលហៅពួកគេថា «អ្នកជ្រមុជទឹកឡើងវិញ» ដែលតាមពិតគេគិតថា ការជ្រមុជទឹកកុមារ គ្មានន័យអីទាំងអស់។ ដូចជាយើងបាននិយាយពីមុន រឿងនេះជាការយល់ឃើញរបស់និកាយ មិនមែនដោយសមាជិកម្នាក់ៗក្នុងនិកាយនោះទេ។ យូណៃធីតមេថូឌីស្ទ ចូលរួមជាមួយគ្រីស្ទបរិសទ្ធភាគច្រើនក្នុងពិភពលោក ដែលយើងផ្តល់សុពលភាពដល់ពិធីជ្រមុជទឹកដែលបានធ្វើក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។ ដូច្នេះ យើងមិនគួរធ្វើពីធីជ្រមុជឡើងវិញ ដោយសារគេជ្រមុជទឹកកាលពីគេនៅក្មេង ឬក៏

---

[72] *Discipline* 2016, paragraph 341.7.

[73] *UMBOW*, paragraph 1, 87.

[74] *Resolutions* 2016, 718-19.

[75] Ibid. See also Article XII "Of Sin After Justification," *Discipline* 2016, paragraph 104, p. 68. សូមចំណាំថា Methodist Article XII ចំឡងតាម Anglican Article XVI "Of Sin After Baptism", លើកលែងតែពាក្យ "justification" ដែលត្រូវបានជំនួសដោយពាក្យ "baptism." BCP 1979, 870.

ពេលចាស់ហើយទទួលបានការប្រែចិត្ត ឬហេតុផលផ្សេងណាទេ។

ដូចយើងបាននិយាយពីពិធីការចុងក្រោយ យើងចាំថាពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ មានទំនាក់ទំនងគ្នា។[76] ពិធីលៀងព្រះអម្ចាស់បង្ហាញពីទំលាប់គ្រីស្ទបរិសទ្ធ ហើយយើងតែធ្វើវាម្តងហើយម្តងទៀត។ ការអរព្រះគុណ និងការទទួលរូបកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ទ យើងមានភាពជិតស្និទ្ធកាន់តែខ្លាំងក្នុងព្រះគុណ ដែលយើងទទួលបានពីពិធីជ្រមុជទឹករបស់យើង។ ដូច្នេះ ការដែលយើងធ្វើពិធីលៀងព្រះអម្ចាស់ញឹកញាប់ គួរធ្វើឲ្យយើងមិនចង់ធ្វើពិធីជ្រមុជទឹកឡើងវិញ។

**សៈ** តើពិធីជ្រមុជទឹកទាក់ទងនិងពិធីដទៃទៀត ដូចជាពិធីចាក់ប្រេងតាំង ពិធីរៀបការ ពិធីបញ្ចុះសព្វ និងពិធីទ្រង់មានព្រះជន្មរស់ឡើងវិញ យ៉ាងដូចម្តេច?

**ចៈ** ពិធីចាក់ប្រេងតាំងរបស់យូណៃធីតមេថូឌីស្ទ គឺជាពិធីព័ន្ធកិច្ចរបស់យូណៃធីតមេថូឌីស្ទ។ គេប្រើពិធីនេះសំរាប់ចាក់ប្រេងតាំងដល់ឌីកិន និងអែលឌឺ និងការតែងតាំងលោកអភិបាល។ សូមចំណាំថា ពិធីទាំងនេះតែងចាប់ផ្តើមដោយការបញ្ជាក់ពីសេចក្តីសញ្ញានៃពិធីជ្រមុជទឹក និងការទទួលស្គាល់នៃព័ន្ធកិច្ចរបស់យើង ទាំងអ្នកដែលទទួលបានប្រេងតាំង និងសមាជិកក្រុមជំនុំ ដែលការទាំងនេះចាក់ឫសទៅក្នុងព្រះគុណរនិងពិធីជ្រមុជទឹក។[77]

ការទាក់ទងគ្នានេះមានក្នុងពិធីរៀបការ ដែលគូស្វាមី ភរិយា ត្រូវប្រកាសគោលបំណង

> ដើម្បីចូលក្នុងសម្ព័ន្ធមេត្រីជាមួយគ្នា
> តាមរយៈព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ
> ដែលបានហៅអ្នកចូលក្នុងរូបកាយរបស់ទ្រង់
> ដែលអ្នកបានទទួលក្នុងពិធីជ្រមុជទឹករបស់អ្នក។[78]

ដូច្នេះសំរាប់ប្តីប្រពន្ធគ្រីស្ទបរិសទ្ធ ពិធីរៀបការ មានទំរង់ជាការរៀបខ្លួនជាសិស្សរបស់ព្រះគ្រីស្ទ ដែលចាក់ឫសក្នុងអត្តសញ្ញាណនៃពិធីជ្រមុជទឹក។

---

[76] *UMBOW*, paragraph 16, 94.

[77] "កម្មវិធីសំរាប់ពន្ធកិច្ចក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ, 2013-2016, ដែលត្រូវបានយល់ព្រម និងកែសម្រួលដោយមហាសន្និបាទសកលឆ្នាំ២០១២" (រៀបចំដោយ by The General Board of Discipleship, The General Board of Higher Education and Ministry and The General Commission on Christian Unity and Inter-religious Concerns in collaboration with The Council of Bishops," 61.

[78] "A Service of Christian Marriage I," *UMBOW*, 117.

ប៉ុន្តែគ្មានអ្វីដែលទាក់ទងជាមួយពិធីជ្រមុជ ដូចជា «ពិធីបុណ្យសព្វ និងការរស់ឡើងវិញ»ទេ។ ពេលដែលសព្វត្រូវបានដាក់ក្នុងក្តាម្ឈូស ពាក្យទាំងនេះត្រូវបាននិយាយ៖

> ក្នុងការស្លាប់ ព្រះគ្រីស្ទបានឈ្នះសេចក្តីស្លាប់
> ការរស់ឡើងវិញ ព្រះគ្រីស្ទបានស្រោចស្រង់ជីវិតយើង
> ព្រះគ្រីស្ទនឹងយាងមកវិញដោយសិរីរុងរឿង
> ដូចក្នុងពិធីជ្រមុជទឹក ឈ្មោះសព្វ ចូលទៅចំពោះព្រះគ្រីស្ទ
> ដូច្នេះក្នុងព្រះគ្រីស្ទ សូមឲ្យ ឈ្មោះសព្វ មានពេញដោយសិរីរុងរឿង[79]

សព្វ ដែលរុំដោយក្រណាត់ស តែងតែមានបំពាក់ឈើឆ្កាង គឺរំលឹកពីសំលៀកបំពាក់ក្នុង ពិធីជ្រមុជទឹក។ ដូច្នេះ ការដែលយើងជាប់ជាមួយនិងពិធីជ្រមុជទឹក អ្នកដែលបានស្លាបទៅ នឹងត្រូវបាននាំចូលក្នុងព្រះវិហារ ដូចដែលឪពុកម្តាយរបស់គេបាននាំគេចូលក្នុងព្រះវិហារ ដើម្បីទទួលពិធីជ្រមុជទឹក។ នេះគឺជាចេតនាយ៉ាងច្បាស់សំរាប់អ្នកគិត។ ព្រះគុណរបស់ព្រះ បានប្រទានមកយើងតាមរយៈពិធីជ្រមុជទឹក  បាននាំយើងមកព្រះវិហារ រចនាជីវិតយើងតាមរយៈកម្មវីធីដែលយើងបានចូលរួម ហើយក្នុងព្រះគុណនេះដែរ ក្រុមជំនុំបាននាំយើងមកដល់ផ្ទះ ថ្វាយយើងទៅព្រះ «ដោយសេចក្តីសង្ឃឹមយ៉ាងជាក់ច្បាស់ ចំពោះការរស់ឡើងវិញទៅកាន់ជីវិតអស់កល្ប តាមរយៈព្រះគ្រីស្ទ។»[80]

---

[79] “A Service of Death and Resurrection,” *UMBOW*, 141.

[80] *UMBOW*, 141.

# សៀវភៅសំរាប់អានផ្សេងទៀត

Benedict, Daniel T., Jr. *Come to the Waters: Baptism and our Ministry of Welcoming Seekers and Making Disciples*. Nashville: Discipleship Resources, 1996.

Bushofsky, Dennis, Suzanne Burke, and Richard Rouse, editors. *Go Make Disciples, An Invitation to Baptismal Living*. Minneapolis: Augsburg Fortress, 2012.

Edie, Fred P. *Book, Bath, Table, and Time: Christian Worship as Source and Resource for Youth Ministry*. Cleveland: The Pilgrim Press, 2007.

Felton, Gayle Carlton. *This Gift of Water: The Practice and Theology of Baptism Among Methodists in America*. Nashville: Abingdon Press, 1992.

Johnson, Maxwell E. *The Rites of Christian Initiation, Their Evolution and Interpretation*. Collegeville, Minnesota: The Liturgical Press, 1999.

Lathrop, Gordon W. *Holy Things, A Liturgical Theology*. Minneapolis: Fortress Press, 1993, 1998.

Stamm, Mark W. *Devoting Ourselves to the Prayers, A Baptismal Theology for the Church's Intercessory Work*. Nashville: Discipleship Ministries, 2014

*Sacraments and Discipleship, Understanding Baptism and the Lord's Supper in a United Methodist Context*. Nashville: Discipleship Resources, 2001. (Updated edition available from OSL Publications, 2013).

Stookey, Laurence Hull. *Baptism, Christ's Act in the Church*. Nashville: Abingdon Press, 1982.

# អំពីអ្នកនិពន្ធ

Mark W. Stamm ទទួលបានសញ្ញាបត្រ័បណ្ឌិតផ្នែកទេវវិទ្យា ពីសកលវិទ្យាល័យបុសស្តុន (University of Boston) និងជាសាស្រ្តាចារ្យផ្នែកការថ្វាយបង្គំគ្រីស្ទបរិសទ្ធ នៅសាលាទេវសាស្រ្តភឺគីនស៍ នៃសកលវិទ្យាល័យមេថូឌីស្ទខាងត្បូង (Perkins School of Theology, Southern Methodist University). លោកបណ្ឌិត Stamm ជាអេលឌឺ (Elder) នៃនិកាយយូណៃធីតមេថូឌីស្ទ និងជាសមាជិកនៃមហាសន្និបាទប្រចាំឆ្នាំតិចសាសខាងជើង។

DISCIPLESHIP MINISTRIES
The United Methodist Church

1908 Grand Avenue
Nashville, TN 37212
UMCdiscipleship.org
877.899.2780
info@UMCdiscipleship.org